N°52/15 15/7/2015

# មាតិកា

## I~ ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ជូនអស់លោក ចំនួន ៤ រូប ៥៦៩១

១៦-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ជូនឯកឧត្តម ចំនួន ២ រូប និងអង្គភាព ចំនួន ៥ អង្គភាព ៥៦៩២

១៧-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤៨ ស្ដីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ៥៦៩៣

១៩-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៤៩ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ដល់លោក **ដឺនីសហ្វ្រង់ស័រឺណេ កូប៉ាំង** (DENIS, FRANÇOIS, RENÉ COPIN) ជនជាតិបារាំង សញ្ជាតិបារាំង ៥៧០៩

១៩-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥០ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឌូ យូស៊ាង** (DU YOUXIANG) ជនជាតិចិន សញ្ជាតិចិន ៥៧១០

១៩-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥១ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **វ៉ាង ស៊ីងអ៊ី** (WANG XINYI) ជនជាតិចិន សញ្ជាតិចិន ៥៧១១

១៩-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥២ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **អាន សាំងគី** (AN SANG KI) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ ៥៧១២

១៩-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥៣ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **វ៉ាង សូចិន** (WANG SU-CHEN) ជនជាតិចិន សញ្ជាតិនូវែលសេឡង់ ៥៧១៣

១៩-៦-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៥៤ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចិន ឡៃ** (CHEN LEI) ជនជាតិចិន សញ្ជាតិចិន ៥៧១៤

# II.រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ

០៨-៧-២០១៥ -អនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពី ការកំណត់ល្បឿនសម្រាប់យានជំនិះ ៥៧១៥

០៨-៧-២០១៥ -អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ឃែរី រើលដ៏ប្រ៊ីដ ឡូជីស្ទីក ៥៧២១

០៩-៧-២០១៥ -អនុក្រឹត្យលេខ ៨៨ អនក្រ.បក ស្តីពី ការកំណត់តំបន់សហគមន៍នៃឧទ្យានជាតិព្រះសីហនុ « រាម » លើផ្ទៃដីទំហំ ៤៩០ ហិកតា ស្ថិតក្នុងភូមិសាស្ត្រ ភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ៥៧២៤

២៩-៦-២០១៥ -អនុក្រឹត្យលេខ ៧១១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៧២៧

២៩-៦-២០១៥ -អនុក្រឹត្យលេខ ៧១២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧២៨

២៩-៦-២០១៥ -អនុក្រឹត្យលេខ ៧១៣ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិកម្ពុជា ៥៧២៩

២៩-៦-២០១៥ -អនុក្រឹត្យលេខ ៧១៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៧៣០

៣០-៦-២០១៥ -អនុក្រឹត្យលេខ ៧១៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៧៣៥

៣០-៦-២០១៥ -អនុក្រឹត្យលេខ ៧១៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៧៣៦

៣០-៦-២០១៥ -អនុក្រឹត្យលេខ ៧១៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៧៣៧

៣០-៦-២០១៥ -អនុក្រឹត្យលេខ ៧១៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧៣៩

៣០-៦-២០១៥ -អនុក្រឹត្យលេខ ៧១៩ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៥៧៤២

៣០-៦-២០១៥ -អនុក្រឹត្យលេខ ៧២០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧៤៣

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៧៤៥

០១-៧-២០១៥ -អនុក្រឹត្យលេខ ៧២២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៧៤៦

## ២.សេចក្តីសម្រេច

០២-៧-២០១៥ -សេចក្តីសម្រេចលេខ ៥១ សសរ ស្តីពី ការបង្កើតគណៈកម្មការស្រាវជ្រាវហេតុការណ៍ ដែលនាំឱ្យកើតមានអំពើហិង្សានៅបង្គោលព្រំដែនលេខ ២០៣ តំបន់ព្រំដែនកម្ពុជា-វៀតណាម ៥៧៤៨

## III.ការងារបណ្តាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ២៩-៥-២០១៥ | -ប្រកាសលេខ ៦៣១ សហវ.ប្រក ស្តីពី ការប្រគល់សិទ្ធិចុះហត្ថលេខា ជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុលើអាណត្តិបើកប្រាក់ "ថាមពល និងទឹក" និង "សោហ៊ុយ ប្រៃសណីយ៍ និងទូរគមនាគមន៍" ជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | ៥៧៥០ |
| ២៩-៥-២០១៥ | -ប្រកាសលេខ ៦៣២ សហវ.ប្រក ស្តីពី ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុលើអាណត្តិបើកប្រាក់ "ថាមពល និងទឹក" និង "សោហ៊ុយ ប្រៃសណីយ៍ និងទូរគមនាគមន៍" ជូនឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | ៥៧៥៣ |
| ២៩-៥-២០១៥ | -ប្រកាសអន្តរក្រសួងលេខ ៦៣៣ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទានរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅសាកលវិទ្យាល័យមានជ័យ | ៥៧៥៦ |
| ០៤-៦-២០១៥ | -ប្រកាសអន្តរក្រសួងលេខ ៦៤១ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាននៅក្រសួងសាធារណការ និងដឹកជញ្ជូន | ៥៧៥៨ |
| ០៤-៦-២០១៥ | -ប្រកាសអន្តរក្រសួងលេខ ៦៤២ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៥ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន | ៥៧៦០ |
| ០៨-៦-២០១៥ | -ប្រកាសអន្តរក្រសួងលេខ ៦៦០ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន របស់ក្រសួងអប់រំ យុវជន និងកីឡា នៅនាយកដ្ឋានសុខភាពសិក្សា | ៥៧៦៥ |


### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


| | | |
|---|---|---|
| ៣០-៤-២០១៥ | -ប្រកាសបង្កើតរោងចក្រលេខ ១៦៩ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដាលី ហ្គាម៉ិន អ៊ិនធើណេសិនណល (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៥៧៦៧ |
| ៣០-៤-២០១៥ | -ប្រកាសបង្កើតរោងចក្រលេខ ១៧០ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេដាង អ៊ិនដាសស្រ្ទៀល បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៥៧៧០ |
| ៣០-៤-២០១៥ | -ប្រកាសបង្កើតរោងចក្រលេខ ១៧១ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឡូធើស ខេរ៉ិត ចឺប៉ែកខូ បង្កើតរោងចក្រ ផលិតបារី | ៥៧៧៣ |
| ៣០-៤-២០១៥ | -ប្រកាសបង្កើតរោងចក្រលេខ ១៧២ ឧស.កឧ.ប្រក.០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេ.អិន.ធី ស៊ូ ហ្វេកធើរី (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្បែកជើង | ៥៧៧៦ |

នស/រកត/០៦១៥/៦៤៦

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

នូវ

## គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

| | | |
|---|---|---|
| ១- | លោក | NGUYEN THANH HUNG |
| ២- | លោក | NGUYEN HUU XUAN |
| ៣- | វរសេនីយ៍ឯក | NGUYEN VAN TIEN |
| ៤- | វរសេនីយ៍ឯកបម្រុង | DON HUNG SON |

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ព៖ល.១៥០៦.៦៥២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥

លេខ:៦៦៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ដូរ**

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

១- ឯកឧត្តម Dinh La Thang
២- ឯកឧត្តម Nguyen Van The
៣- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងដឹកជញ្ជូនវៀតណាម
៤- នាយកដ្ឋានផែនការនិងវិនិយោគ ក្រសួងដឹកជញ្ជូនវៀតណាម
៥- សាជីវកម្មសំណង់វិស្វកម្មស៊ីវិល ទី១(CIENCO 1)
៦- វិទ្យាស្ថានរចនាប្លង់វិស្វកម្មដឹកជញ្ជូន(TEDI)
៧- អង្គភាពអនុវត្តគម្រោងទី៧(PMU7)

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារល.១៥០៦.៦៥៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៦៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៤៨

## ស្តីពី

## លក្ខន្តិកៈដោយឡែក
## នៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងបង្កើតក្របខណ្ឌដោយឡែករបស់អ្នករាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសរសេរកាត់ថា "អ.គ.ជ.ប" ដើម្បីកំណត់សិទ្ធិ តួនាទី ភារកិច្ច និងការទទួលខុសត្រូវ។

**មាត្រា២ .-**

ព្រះរាជក្រឹត្យនេះ មានគោលដៅកំណត់អំពីក្របខណ្ឌ ឋានន្តរសក្តិ ថ្នាក់ មុខតំណែង លក្ខខណ្ឌនៃការជ្រើសរើស ការធ្វើកម្មសិក្សា ការតាំងស៊ប់ ការបញ្ចេញពីក្របខណ្ឌ ការតែងតាំង ការដំឡើងឋានន្តរសក្តិ និងថ្នាក់ ការឈប់សម្រាក ការដាក់ទណ្ឌកម្មវិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ និងការចូលនិវត្តន៍របស់ អ.គ.ជ.ប។

**មាត្រា៣ .-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះ អ.គ.ជ.ប ដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និងលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដែលសរសេរកាត់ថា "លធ.ខប"។

អ.គ.ជ.ប ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ គ.ជ.ប។

## ជំពូកទី២
## ក្របខណ្ឌ ឋានន្តរសក្តិ ថ្នាក់ និងមុខតំណែង

**មាត្រា៤ .-**

ក្របខណ្ឌរបស់ អ.គ.ជ.ប ត្រូវបានបែងចែកជា៣ (បី) ប្រភេទគឺ៖

១- **ប្រភេទ ក** - ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់

២- **ប្រភេទ ខ** - ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម

៣- **ប្រភេទ គ** - ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម។

**មាត្រា៥ .-**

ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ត្រូវបានបែងចែកជា៣ (បី) ឋានន្តរសក្តិ៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- ឧត្តមមន្ត្រីមាន ៦ថ្នាក់
- វរមន្ត្រីមាន ៤ថ្នាក់
- អនុមន្ត្រីមាន ៤ថ្នាក់។

**មាត្រា៦ ._**

ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យមត្រូវបានបែងចែកជា៣ (បី) ឋានន្តរសក្តិ៖

- នាយក្រមការមាន ៦ថ្នាក់
- ក្រមការដើមខ្សែមាន ៤ថ្នាក់
- ក្រមការមាន ៤ថ្នាក់។

**មាត្រា៧ ._**

ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋមមាន ១០ថ្នាក់។

**មាត្រា៨ ._**

ការរៀបចំសន្ទស្សន៍បៀវត្សនៃថ្នាក់នីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប អនុលោមតាមគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។ ការកំណត់ និងការកែប្រែតម្លៃឯកតាសន្ទស្សន៍បៀវត្ស ត្រូវអនុវត្តអនុលោមតម្លៃឯកតាសន្ទស្សន៍នៃបៀវត្ស របស់មន្ត្រីរាជការស៊ីវិល ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៩ ._**

អ.គ.ជ.ប ក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ មានមុខងារសម្រាប់កាន់មុខតំណែង ជាអ្នកដឹកនាំ គ្រប់គ្រង អធិការកិច្ច សវនកម្ម បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់យោបល់ គោលនយោបាយ ផែនការ និងមុខងារក្នុងរាល់មុខតំណែងទទួលខុសត្រូវ។

អ.គ.ជ.ប ក្នុងឋានន្តរសក្តិឧត្តមមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអគ្គ លេខាធិការ អគ្គលេខាធិការរង និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាន នៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ.គ.ជ.ប ក្នុងឋានន្តរសក្តិវរមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាប្រធាន នាយកដ្ឋាន និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ.គ.ជ.ប ក្នុងឋានន្តរសក្តិអនុមន្ត្រី មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធាននាយកដ្ឋាន ប្រធាន លធ.ខប និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

មុខតំណែង និងការពិព័ណ៌នាអំពីលក្ខខណ្ឌការងារនៃ អ.គ.ជ.ប ដែលកំពុងបំពេញភារកិច្ចនៅក្នុងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និង លធ.ខប នឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

**មាត្រា១០ .-**

អ.គ.ជ.ប ក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម មានមុខងារក្នុងការរៀបចំការងារសម្រាប់អ្នកទទួលខុសត្រូវសម្រេច និងដាក់ឱ្យអនុវត្តការងារ បណ្តុះបណ្តាល ធានាប្រតិបត្តិការនៃការងារ និងជួយគាំទ្រដល់ការងារមន្ត្រីក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់។

អ.គ.ជ.ប ក្នុងឋានន្តរសក្តិនាយក្រមការ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធាន លធ.ខប ប្រធានការិយាល័យ និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ.គ.ជ.ប ក្នុងឋានន្តរសក្តិក្រមការដើមខ្សែ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាអនុប្រធានការិយាល័យ និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

អ.គ.ជ.ប ក្នុងឋានន្តរសក្តិក្រមការ មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងមន្ត្រីជំនាញ និងមុខតំណែងឯទៀតដែលមានឋានៈស្មើ ហើយដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន។

**មាត្រា១១ .-**

អ.គ.ជ.ប ក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម មានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាលេខាធិការ និងជាការីការងាររដ្ឋបាល។

**មាត្រា១២ .-**

អ.គ.ជ.ប ដែលមានឋានន្តរសក្តិក្នុងមុខតំណែងណាមួយ អាចត្រូវផ្លាស់ប្តូរទៅកាន់មុខតំណែងផ្សេងទៀតបាន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា១៣ .-**

ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់បោះឆ្នោត ប្រាក់ឧបត្ថម្ភពេលប្រតិបត្តិការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត ប្រាក់វិភាជន៍គ្រួសារ ប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗនៃ អ.គ.ជ.ប ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។ របបសន្តិសុខសង្គមដែលរួមមាន សោធននិវត្តន៍ សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និងតាវកាលិកផ្សេងៗទៀត ត្រូវអនុវត្តអនុលោមបទប្បញ្ញត្តិ និងនីតិវិធីដែលមានជាធរមានសម្រាប់មន្ត្រីរាជការស៊ីវិលដែលស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៤ .-**

សញ្ញាសក្តិ និងឯកសណ្ឋានសម្រាប់ អ.គ.ជ.ប ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើរបស់ប្រធាន គ.ជ.ប។

## ជំពូកទី៣
## ការជ្រើសរើសឱ្យចូលធ្វើការ

**មាត្រា១៥ .-**

រាល់ការជ្រើសរើស អ.គ.ជ.ប ក្នុងក្របខណ្ឌណាមួយ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង។ ការជ្រើសរើសត្រូវបានលើកទឹកចិត្តចំពោះបេក្ខជនជាស្ត្រី ជនជាតិដើមភាគតិច និងជនដែលមានពិការភាព។

**មាត្រា១៦ .-**

បេក្ខជនទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- មានសញ្ជាតិខ្មែរ

២- មានអាយុពី១៨ (ដប់ប្រាំបី) ឆ្នាំឡើង រហូតដល់អាយុ៣៥ (សាមសិបប្រាំ) ឆ្នាំគិតមកដល់ថ្ងៃប្រឡង

៣- មានសំបុត្រថ្កោលទោស

៤- មានកិរិយាមារយាទល្អ

៥- មានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងសេចក្តីត្រូវការ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១៧ .-**

កាលបរិច្ឆេទនៃការប្រឡងជ្រើសរើសត្រូវផ្សព្វផ្សាយជាសាធារណៈឱ្យបាន៦០ (ហុកសិប) ថ្ងៃ មុនពេលប្រឡង។ ក្នុងករណីប្រញាប់ ការផ្សព្វផ្សាយត្រូវធ្វើយ៉ាងតិច៣០ (សាមសិប) ថ្ងៃមុន។

**មាត្រា១៨ .-**

ការប្រឡងចូលក្របខណ្ឌណាមួយ គ.ជ.ប ត្រូវតែងតាំងគណៈកម្មការជ្រើសរើសមួយ ដែលមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- អ.គ.ជ.ប ២ (ពីរ) នាក់ក្នុងក្របខណ្ឌជាមួយ | សមាជិក។ |

**មាត្រា១៩ .-**

អាចប្រឡងចូលក្របខណ្ឌៈ

- មន្ត្រីបោះឆ្នោតជាន់ខ្ពស់ បេក្ខជនដែលមានសញ្ញាបត្រកម្រិតអប្បបរមាបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល។
- មន្ត្រីបោះឆ្នោតមធ្យម បេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូកវគ្គបណ្តុះបណ្តាលរយៈពេល២ (ពីរ) ឆ្នាំ ដោយមានវិញ្ញាបនបត្រ ឬសញ្ញាបត្រ ឬ/និងមន្ត្រីស្ថិតក្នុងក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ដែលកំពុងបំពេញការងារនៅអគ្គលេខាធិការដ្ឋាន គ.ជ.ប ឬ លធ.ខប។
- មន្ត្រីបោះឆ្នោតបឋម បេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

**មាត្រា២០ .-**

ផែនការតម្រូវការចំនួន អ.គ.ជ.ប ប្រចាំឆ្នាំ ជាសមត្ថកិច្ចរបស់ គ.ជ.ប តាមសេចក្តីស្នើរបស់អគ្គលេខាធិការ។

ក្នុងករណីចាំបាច់ គ.ជ.ប អាចសម្រេចតែងតាំង អ.គ.ជ.ប តាមតម្រូវការជាក់ស្តែង។

## ជំពូកទី៤
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខណ្ឌ ការបញ្ចេញពីក្របខណ្ឌ

**មាត្រា២១ .-**

រយៈពេលកម្មសិក្សាត្រូវកម្រិត១២ (ដប់ពីរ) ខែ។ រយៈពេលកម្មសិក្សាត្រូវគិតតាំងពីថ្ងៃតែងតាំងកម្មសិក្សាការីនោះ។

កម្មសិក្សានេះមិនត្រូវយកជាការបានទេ បើកាលណាសាមីជនខកខានពុំបានមកធ្វើកម្មសិក្សាសរុប៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីនេះ សាមីជនត្រូវបន្តធ្វើកម្មសិក្សានៅលើកទី២ ទៀត។ ការបន្តធ្វើកម្មសិក្សាលើកទី២ ត្រូវមានរយៈពេលស្មើនឹងរយៈពេលលើកទី១ ដែរ។

មិនបាច់ធ្វើកម្មសិក្សា ចំពោះ អ.គ.ជ.ប ទាំងឡាយដែលបានប្រឡងជាប់ទៅកាន់ក្របខណ្ឌខ្ពស់ជាងនៃជំនាញដែលខ្លួនធ្លាប់ជា អ.គ.ជ.ប ចាស់ ដោយបានតាំងស៊ប់ក្នុងក្របខណ្ឌម្តងរួចមកហើយ។

**មាត្រា២២ .-**

ការតាំងស៊ប់ត្រូវសម្រេចក្នុងរយៈពេលមិនលើសពី៣ (បី) ខែ ក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា។

ការតាំងស៊ប់ចាប់ផ្តើមមានប្រសិទ្ធភាពខាងផ្នែកបៀវត្ស ក៏ដូចជាអតីតភាពការងារសម្រាប់ឡើងថ្នាក់។ ប៉ុន្តែអតីតភាពការងារសម្រាប់ចូលនិវត្តន៍ត្រូវបានគិតបញ្ចូលតាំងពីពេលចាប់ផ្តើមធ្វើកម្មសិក្សា។ ការតាំងស៊ប់ត្រូវសម្រេចដោយ គ.ជ.ប បន្ទាប់ពីមានការផ្តល់យោបល់ពីគណៈកម្មការវាយតម្លៃមួយដែលមានសមាសភាពដូចតទៅៈ

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- អ.គ.ជ.ប ២ (ពីរ) នាក់ ដែលមានក្របខណ្ឌដូចគ្នា | សមាជិក។ |

**មាត្រា២៣ .-**

កម្មសិក្សាការី ណាដែលមិនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ធ្វើការខ្ជីខ្ជា មិនគោរពវិន័យ ឬគ្មានកម្លាំងពលំនឹងកាន់មុខតំណែងបាន អាចត្រូវបានបញ្ឈប់មិនឱ្យធ្វើការ ឬផ្ទេរទៅកាន់ក្របខណ្ឌដើមវិញ ពេលណាក៏បាន ក្នុងរយៈពេលបំពេញកម្មសិក្សា។

**មាត្រា២៤ .-**

អ.គ.ជ.ប ណា ដែលធ្វើការតទៅទៀតមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈ ហើយដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលសោធននិវត្តន៍ ត្រូវបានចាត់ទុកថា បាត់បង់សមត្ថភាពការងារ ហើយត្រូវបញ្ឈប់មិនឱ្យធ្វើការតទៅទៀត។

ក្នុងករណីនេះ សាមីជនត្រូវបានទទួលប្រាក់ធានារ៉ាប់រងសង្គមម្តងគត់ និងប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍។ បើ អ.គ.ជ.ប នោះមានអតីតភាពការងារលើសពី២០ (ម្ភៃ) ឆ្នាំ សាមីជនត្រូវបានតម្រូវឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ ដោយទទួលប្រាក់សោធននិវត្តន៍សមាមាត្រ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសម្រេចដោយ គ.ជ.ប បន្ទាប់ពីមានការផ្តល់យោបល់ពីគណៈកម្មការដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | តំណាង គ.ជ.ប | ប្រធាន |
| ២- | អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- | ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- | ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- | គ្រូពេទ្យដែលបានទទួលសញ្ញាប្រណិធាន និងដែលត្រូវបានចាត់ឡើងដោយក្រសួងសុខាភិបាល | សមាជិក |
| ៦- | អ.គ.ជ.ប ដែលមានក្របខណ្ឌជាមួយគ្នា១ (មួយ) នាក់ ដែលមានឋានន្តរសក្តិយ៉ាងហោចណាស់ស្មើនឹងសាមីជន | សមាជិក។ |

## ជំពូកទី៥
## ការតែងតាំង ការដំឡើងឋានន្តរសក្តិ ថ្នាក់ និងគ្រឿងឥស្សរិយយស

**មាត្រា២៥ .-**

ការតែងតាំងសម្រាប់ អ.គ.ជ.ប ឱ្យកាន់មុខតំណែងណាមួយ ត្រូវតែផ្អែកតាមអង្គការលេខនៃរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានដែលមានកន្លែងទំនេរ។

**មាត្រា២៦ .-**

នៅក្របខណ្ឌនីមួយៗ អ.គ.ជ.ប ក្នុងឋានន្តរសក្តិ ឬថ្នាក់ណាមួយ មិនអាចចាត់ឱ្យទៅធ្វើការក្រោមបង្គាប់ អ.គ.ជ.ប ម្នាក់ទៀត ដែលមានឋានន្តរសក្តិ ឬថ្នាក់ទាបជាងខ្លួនទេ លើកលែងតែក្នុងករណីចាំបាច់ ហើយសាមីខ្លួនដែលមានឋានន្តរសក្តិ ឬថ្នាក់ធំជាងនោះយល់ព្រម។

**មាត្រា២៧ ..**

ការដំឡើងថ្នាក់ជូន អ.គ.ជ.ប ត្រូវធ្វើតាមវេនជ្រើសរើសក៏បាន ឬតាមវេនជ្រើសរើស និងអតីតភាពជាមួយគ្នាក៏បាន។

**មាត្រា២៨ ..**

ការដំឡើងថ្នាក់ជូន អ.គ.ជ.ប ត្រូវកំណត់តាមលក្ខខណ្ឌដូចខាងក្រោម៖

១- មានអតីតភាពការងារ២ (ពីរ) ឆ្នាំយ៉ាងតិច

២- មានលទ្ធផលល្អក្នុងការបំពេញការងារ

៣- គោរពវិន័យបានល្អ

៤- មានសាមគ្គីភាពផ្ទៃក្នុងល្អ។

ក្នុងករណីមាន អ.គ.ជ.ប ណាបំពេញការងារបានល្អវិសេស អ.គ.ជ.ប នោះត្រូវបានដំឡើងថ្នាក់ជាស្វ័យប្រវត្តិ ដោយមិនគិតពីលក្ខខណ្ឌអតីតភាពការងារឡើយ។

ការដំឡើងថ្នាក់នៅក្នុងឋានន្តរសក្តិឧត្តមមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធាន គ.ជ.ប ផ្អែកតាមការសម្រេចរបស់ គ.ជ.ប។ ការដំឡើងថ្នាក់ក្នុងឋានន្តរសក្តិវរមន្ត្រី និងឋានន្តរសក្តិអនុមន្ត្រីនៃក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ និងក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

**មាត្រា២៩ ..**

អ.គ.ជ.ប ក្នុងក្របខណ្ឌណាមួយអាចឡើងថ្នាក់បាន ម្តងមួយថ្នាក់។

នៅពេល អ.គ.ជ.ប ត្រូវប្តូរក្របខណ្ឌខ្ពស់ទៀតដោយសារបានប្រឡងជាប់ សន្ទស្សន៍បៀវត្សត្រូវគិតតាមឋានន្តរសក្តិដំបូងនៃក្របខណ្ឌថ្មី។ ប៉ុន្តែបើបៀវត្សនៅទាបជាងបៀវត្សចាស់ ត្រូវរៀបត្រឹមថ្នាក់ដែលមានកម្រិតស្មើ ឬខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សក្របខណ្ឌចាស់នៃ អ.គ.ជ.ប នោះ។ អតីតភាពការងារដើម្បីដំឡើងថ្នាក់ត្រូវគិតពីថ្ងៃដែលបានទទួលបៀវត្សថ្នាក់ចុងក្រោយ។

ការដំឡើងថ្នាក់ត្រូវសម្រេចដោយ គ.ជ.ប និងស្របតាមកម្រិតមុខចំណាយថវិកា។

**មាត្រា៣០ ..**

អ.គ.ជ.ប ក្របខណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ ដែលមានសញ្ញាបត្រខ្ពស់ជាងបរិញ្ញាបត្រ ត្រូវបានដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ។

អ.គ.ជ.ប ក្របខណ្ឌមន្ត្រីបោះឆ្នោតមធ្យម ដែលមានបរិញ្ញាបត្រ ឬសញ្ញាបត្រមានតម្លៃសមមូល ត្រូវបានដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ។

អ.គ.ជ.ប ក្របខណ្ឌមន្ត្រីបោះឆ្នោតបឋម ដែលមានសញ្ញាបត្រខ្ពស់ជាងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ត្រូវបានដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ។

**មាត្រា៣១ .-**

ជារៀងរាល់ឆ្នាំ នៅខែមករា នាយកដ្ឋានរដ្ឋបាលត្រូវចុះបញ្ជីនៃ អ.គ.ជ.ប ដែលមានសិទ្ធិត្រូវដំឡើងថ្នាក់ ដោយបញ្ជូនព្រឹត្តិបត្រពិន្ទុទៅការិយាល័យ និងនាយកដ្ឋានសាមីដើម្បីដាក់ពិន្ទុ និងចុះមូលវិចារណ៍ដល់សាមីជនម្នាក់ៗ។ បន្ទាប់ពីដាក់ពិន្ទុ និងចុះមូលវិចារណ៍រួចហើយ ការិយាល័យ និងនាយកដ្ឋានសាមី ត្រូវបញ្ជូនព្រឹត្តិបត្រពិន្ទុទាំងនោះទៅនាយកដ្ឋានរដ្ឋបាលវិញ ដើម្បីធ្វើបញ្ជីចំណាត់ថ្នាក់រួម សម្រាប់រាយការណ៍ជូនគណៈកម្មការដំឡើងថ្នាក់។

**មាត្រា៣២ .-**

អគ្គលេខាធិការបញ្ឈប់បញ្ជី អ.គ.ជ.ប ដែលត្រូវបានស្នើពិនិត្យដំឡើងថ្នាក់ រួចបញ្ជូនទៅគណៈកម្មការដំឡើងថ្នាក់ ដើម្បីធ្វើការប្រជុំ។

សមាសភាពគណៈកម្មការដំឡើងថ្នាក់មានដូចតទៅ៖

| | |
|---|---|
| ១- តំណាង គ.ជ.ប | ប្រធាន |
| ២- អគ្គលេខាធិការ ឬតំណាង | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៤- ប្រធាននាយកដ្ឋានពាក់ព័ន្ធ | សមាជិក |
| ៥- អ.គ.ជ.ប ដែលមានក្របខណ្ឌជាមួយ ២ (ពីរ) នាក់ | សមាជិក។ |

**មាត្រា៣៣ .-**

ការដំឡើងថ្នាក់ត្រូវធ្វើនៅខែមេសានៃឆ្នាំនីមួយៗ។

អ.គ.ជ.ប ដែលមានឈ្មោះក្នុងបញ្ជី ប៉ុន្តែមិនបានឡើងថ្នាក់ មានអាទិភាពក្នុងការដំឡើងថ្នាក់នាឆ្នាំបន្ទាប់។ អ.គ.ជ.ប ម្នាក់ៗមានសិទ្ធិសុំមើលដោយស្ងាត់កំបាំងនូវសំណុំរឿងផ្ទាល់ខ្លួន។

**មាត្រា៣៤ .-**

សិទ្ធិឡើងថ្នាក់ត្រូវផ្អាកទុកសិនចំពោះ អ.គ.ជ.ប ណាដែលទទួលទណ្ឌកម្មថ្នាក់ទី២ ផ្នែកវិន័យ ឬទទួលការចោទប្រកាន់តាមផ្លូវតុលាការ និងអ្នកដែលត្រូវបានដាក់ឱ្យនៅទំនេរគ្មានបៀវត្សចាប់ពីរយៈពេល៦ (ប្រាំមួយ) ខែឡើងទៅ។

ROYAUME … LE MINISTRE DU PALAIS

**មាត្រា៣៥ .-**

អ.គ.ជ.ប ដែលមានស្នាដៃល្អក្នុងការបំពេញការងារ អាចទទួលគ្រឿងឥស្សរិយយស។

លក្ខខណ្ឌ និងបែបបទនៃការផ្តល់គ្រឿងឥស្សរិយយស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

ឋានន្តរសក្តិកិត្តិយសអាចផ្តល់ដោយ គ.ជ.ប ជូន អ.គ.ជ.ប ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ធ្វើការដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព បន្ទាប់ពីបានបំពេញការងារអស់រយៈពេលយូរ និងមានស្នាដៃល្អ។

## ជំពូកទី៦
## ការឈប់សម្រាក

**មាត្រា៣៦ .-**

អ.គ.ជ.ប មានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំចំនួន១៥ (ដប់ប្រាំ) ថ្ងៃ បន្ថែមពីលើថ្ងៃឈប់សម្រាកដែលកំណត់ដោយរាជរដ្ឋាភិបាល។

អ.គ.ជ.ប នារីមានសិទ្ធិឈប់សម្រាកលំហែមាតុភាពចំនួន៩០ (កៅ សិប) ថ្ងៃ។

អ.គ.ជ.ប ដែលមានធុរៈអាចត្រូវបានអនុញ្ញាតច្បាប់ឱ្យឈប់សម្រាកពីការងារ។

**មាត្រា៣៧ .-**

អ.គ.ជ.ប ដែលមានអតីតភាពការងារយ៉ាងតិច៣ (បី) ឆ្នាំ មានសិទ្ធិស្នើសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដែលមានរយៈពេលម្តងៗ មិនតិចជាង៦ (ប្រាំមួយ) ខែ និងមិនលើសពី២ (ពីរ) ឆ្នាំ ហើយអាចបន្តជាថ្មី សរុបទាំងអស់មិនឱ្យហួសពី៤ (បួន) ឆ្នាំ។

បែបបទលក្ខខណ្ឌ និងរយៈពេលនៃការឈប់នេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

## ជំពូកទី៧
## វិន័យ

**មាត្រា៣៨ .-**

អ.គ.ជ.ប គ្រប់រូបត្រូវប្រតិបត្តិតាមច្បាប់ បទបញ្ជាផ្ទៃក្នុង គ.ជ.ប ក្រមសីលធម៌ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ហើយត្រូវគោរពគោលការណ៍អព្យាក្រឹតឥតលម្អៀង មិនប្រកាន់គណបក្សនយោបាយក្នុងពេលបំពេញការងារ។ អ.គ.ជ.ប ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះ គ.ជ.ប អំពីកិច្ចការ និងអំពើរបស់ខ្លួនដែលបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយសនៃ អ.គ.ជ.ប ទោះបីកិច្ចការនោះប្រព្រឹត្តនៅមជ្ឈដ្ឋានខាងក្រៅក៏ដោយ។

**មាត្រា៣៩ ..**

អ.គ.ជ.ប  រាល់រូបមិនអាចអវត្តមានដោយគ្មានការអនុញ្ញាត  ឬដោយគ្មានមូលហេតុត្រឹមត្រូវបានឡើយ។

អវត្តមានដោយគ្មានការអនុញ្ញាត  ឬដោយគ្មានមូលហេតុត្រឹមត្រូវអាចឱ្យ  អ.គ.ជ.ប នោះទទួលទណ្ឌកម្មខាងវិន័យ។

**មាត្រា៤០ ..**

អ.គ.ជ.ប មិនត្រូវះ

- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួន
- ប្រើឥទ្ធិពល និងអំណាចក្នុងមុខងាររបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬសំឡុតគំរាមកំហែងបំពានសិទ្ធិរបស់ពលរដ្ឋ
- គ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល
- បោះពុម្ពផ្សាយ  ឬផ្សព្វផ្សាយព័ត៌មានដែលទាក់ទងនឹងការងាររបស់  គ.ជ.ប ដោយគ្មានការអនុញ្ញាតជាមុនពី គ.ជ.ប។

អំពើបំពាននឹងបទប្បញ្ញត្តិនៃមាត្រានេះ  អាចបណ្តាលឱ្យទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង។

**មាត្រា៤១ ..**

ទណ្ឌកម្មខាងវិន័យមានដូចតទៅះ

**១- ទណ្ឌកម្មថ្នាក់ទី ១**

ក-  ស្តីបន្ទោស

ខ-  ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ-  ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ។

**២- ទណ្ឌកម្មថ្នាក់ទី ២**

ក-  លុបឈ្មោះចេញពីបញ្ជីដំឡើងថ្នាក់  បើសិនជាមានចុះឈ្មោះហើយ  ឬមិនដំឡើងថ្នាក់ក្នុងថេរវេលាមួយមិនលើសពី២ (ពីរ) ឆ្នាំ

ខ-  ដាក់ឱ្យនៅទំនេរគ្មានបៀវត្សមិនលើសពី១ (មួយ) ឆ្នាំ

គ-  បន្ថយឋានន្តរសក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់

ឃ- ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ

ង- បណ្តេញចេញពីមុខតំណែងរាជការ។

លក្ខខណ្ឌស្តីពីទណ្ឌកម្មវិន័យចំពោះ អ.គ.ជ.ប ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

## ជំពូកទី៨
## ការចោទប្រកាន់តាមផ្លូវតុលាការ

**មាត្រា៤២ .-**

អ.គ.ជ.ប ដែលត្រូវបានតុលាការកំពុងចោទប្រកាន់ ហើយដែលត្រូវបានបញ្ជូនខ្លួនឱ្យតុលាការជំនុំជម្រះអាចត្រូវបានផ្អាកការងារសិនក្នុងករណីចាំបាច់។

ក្នុងករណីដែល អ.គ.ជ.ប ណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះទៅ គ.ជ.ប ក្នុងរយៈពេល៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ។

ក្នុងករណីដែលបទល្មើសនោះ កើតមានក្នុងក្របខណ្ឌនៃការបម្រើការងារបោះឆ្នោត គ.ជ.ប ត្រូវការពារ អ.គ.ជ.ប នោះតាមផ្លូវច្បាប់។

**មាត្រា៤៣ .-**

ក្នុងករណីដែល អ.គ.ជ.ប ត្រូវបានផ្អាកពីការងារបណ្តាលមកពីជាប់ចោទតាមផ្លូវតុលាការជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ហើយត្រូវបានតុលាការសម្រេចថា គ្មានទោស អ.គ.ជ.ប នោះត្រូវបានអនុញ្ញាតឱ្យចូលធ្វើការវិញភ្លាម ដោយគិតពីអតីតភាព ឋានន្តរសក្តិ សោធននិវត្តន៍ និងទទួលបៀវត្សប្រតិសកម្មផង។

**មាត្រា៤៤ .-**

អ.គ.ជ.ប ដែលតុលាការបានកាត់ទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋត្រូវលុបឈ្មោះចេញពី អ.គ.ជ.ប ចាប់ពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ។

## ជំពូកទី៩
## ការចូលនិវត្តន៍

**មាត្រា៤៥ .-**

អ.គ.ជ.ប ត្រូវបានដាក់ឱ្យចូលនិវត្តន៍នៅអាយុ៦០ (ហុកសិប) ឆ្នាំ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៦ .-**

អ.គ.ជ.ប ដែលដល់អាយុចូលនិវត្តន៍ ហើយមានអតីតភាពការងារក្នុងចន្លោះពី២០ (ម្ភៃ) ឆ្នាំដល់ក្រោម៣០ (សាមសិប) ឆ្នាំ ត្រូវបានទទួលប្រាក់សោធននិវត្តន៍សមាមាត្រ។

**មាត្រា៤៧ .-**

អ.គ.ជ.ប ដែលដល់អាយុចូលនិវត្តន៍ ហើយមានអតីតភាពការងារ៣០ (សាមសិប) ឆ្នាំយ៉ាងតិចត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព។ ប៉ុន្តែ អ.គ.ជ.ប ដែលបម្រើការងារអស់រយៈពេល៣០ (សាមសិប) ឆ្នាំ អាចសុំចូលនិវត្តន៍មុនដល់អាយុត្រូវចូលនិវត្តន៍បាន ដោយត្រូវបានទទួលប្រាក់សោធននិវត្តន៍អតីតភាព។

**មាត្រា៤៨ .-**

អ.គ.ជ.ប ដែលបានបម្រើការងារក្រោម២០ (ម្ភៃ) ឆ្នាំ ហើយដល់អាយុចូលនិវត្តន៍ ត្រូវទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗតែមួយលើក។

**មាត្រា៤៩ .-**

ចំពោះ អ.គ.ជ.ប ដែលមានអតីតភាពការងារគ្រប់៣០ (សាមសិប) ឆ្នាំហើយ ហើយមិនទាន់ដល់អាយុចូលនិវត្តន៍ទេនោះ មិនត្រូវបានកាត់ទុកប្រាក់សោធននិវត្តន៍ឡើយ។

**មាត្រា៥០ .-**

អតីតភាពការងារសម្រាប់ចូលនិវត្តន៍របស់ អ.គ.ជ.ប ត្រូវគិតតាំងពីថ្ងៃដែលសាមីជនចូលបម្រើការងាររដ្ឋ ទោះក្នុងសម័យណាក៏ដោយ។

## ជំពូកទី១០
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា៥១ .-**

ប្រធាន គ.ជ.ប អនុប្រធាន គ.ជ.ប និងសមាជិក គ.ជ.ប អាចចាត់តាំងមន្ត្រីមួយចំនួនឱ្យបម្រើការងារផ្ទាល់ តាមអង្គការលេខរបស់ គ.ជ.ប ទោះបីសាមីជននោះពុំមែនជាមន្ត្រីក្របខណ្ឌក៏ដោយ។ ក្នុងករណីនេះ សាមីជនដែលទទួលការតែងតាំងមានសិទ្ធិទទួលប្រាក់បំណាច់ដោយធម្មតា តែគ្មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ទេ ហើយបញ្ចប់មុខតំណែងរបស់ខ្លួនតាមអាណត្តិរបស់ គ.ជ.ប។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា៥២ .-**

ផ្អែកលើការចាំបាច់ក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងពេលបោះឆ្នោត គ.ជ.ប អាចជ្រើសរើស និងតែងតាំងមន្ត្រីចាំបាច់មួយចំនួនឱ្យបម្រើការងារ ទោះបីសាមីជននោះពុំមែនជាមន្ត្រីក្របខណ្ឌក៏ដោយ។ ក្នុងករណីនេះ សាមីជនមានសិទ្ធិទទួលប្រាក់បំណាច់ជាធម្មតាទៅតាមកិច្ចសន្យា តែមិនមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ទេ ហើយបញ្ចប់មុខតំណែងរបស់ខ្លួនតាមការកំណត់របស់ គ.ជ.ប។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៥៣ .-**

អគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃ គ.ជ.ប ត្រូវបន្តការងារជាអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃ គ.ជ.ប ដែលបានរៀបចំឡើងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប រហូតដល់មានការតែងតាំងថ្មី ស្របតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប។

ការផ្លាស់ប្តូរ និងតែងតាំងអគ្គលេខាធិការ អគ្គលេខាធិការរង មន្ត្រី បុគ្គលិកនៃ គ.ជ.ប ត្រូវធ្វើឡើងដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប។

មន្ត្រី បុគ្គលិកដែលកំពុងបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប និង លធ.ខប ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌនៃលក្ខន្តិកៈដោយឡែក ដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រា៥៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប។

គោលការណ៍នៃការធ្វើសមាហរណកម្មមន្ត្រី បុគ្គលិកដែលកំពុងបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប និង លធ.ខប បច្ចុប្បន្ន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

**មាត្រា៥៤ .-**

ចាប់ពីព្រះរាជក្រឹត្យនេះ ចូលជាធរមាន អ.គ.ជ.ប ដែលមានអាយុលើសពីការកំណត់ អាចអនុញ្ញាតបន្តឱ្យធ្វើការបានតាមការស្នើសុំរបស់សាមីខ្លួន១ (មួយ) ឆ្នាំម្តងៗ និងតាមការសម្រេចពី គ.ជ.ប ដោយសំឡេងភាគច្រើនដាច់ខាត តាមតម្រូវការជាក់ស្តែង ផ្អែកលើយោបល់របស់អគ្គលេខាធិការ និងប្រធានអង្គភាពសាមី។

ការស្នើសុំពន្យារនេះ មិនឱ្យលើសពី៤ (បួន) ដងទេ។

**ជំពូកទី១២**

**អវសានប្បញ្ញត្តិ**

**មាត្រា៥៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៦ ._**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ចារក.១៥០៦.៦៥៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ហត្ថលេខា**

**ស៊ិក ប៊ុនហុក**

លេខៈ ៦៦៨ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៥/៦៤៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **ដឺនីសហ្វ្រង់ស័វរីណេ កូប៉ាំង** (DENIS, FRANÇOIS,RENÉ COPIN) ជនជាតិបារាំង សញ្ជាតិបារាំង កើតថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៦៨ នៅក្រុងប៉ារីស សាធារណរដ្ឋបារាំង ដោយសុំប្តូរឈ្មោះជា **ដឺនីស កូប៉ាំង** (DENIS COPIN)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរ៧. ១៥០៦. ៦៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៥

លេខៈ ៦៥៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៥០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឌូ យូស៊ាង** (DU YOUXIANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧១ នៅខេត្តស៊ីឈួន សាធារណរដ្ឋប្រជាមានិតចិន ដោយសុំប្តូរឈ្មោះជា **យូ សៀន** (YOU SEAN)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥០៦. ៦៥៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៦៥៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៥១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **វ៉ាង ស៊ីនអ៊ី** (WANG XINYI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៨៦ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៣៧.១៥០៦.៦៥៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៥*

លេខៈ ៦៥៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៥/៦៥៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អាន សាំងគី** (AN SANG KI) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦១ នៅខេត្តឃីងស៊ីហ្គូ សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **អាន សុខហេង** (AN SOKHENG)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

០៣៧.១៥០៦.៦៥៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៥*

លេខ: ៧៥៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៥/៦៥៣

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់បង្គាប់

**មាត្រា ១ :** ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **វ៉ាង សុចិន** (WANG SU-CHEN) ជនជាតិចិន សញ្ជាតិនូវែលសេឡង់ កើតថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៥៦ នៅក្រុងយុនលីន (YUNLIN) សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣៧. ១៥០៦. ៦៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៥

លេខៈ ៦៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៦១៥/៦៥៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរជាតិរាស្ត្រ ពុទ្ធិន្ទ្រធរាមហាក្សត្រ**
**ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសញ្ជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចិន ឡៃ** (CHEN LEI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧២ នៅខេត្តអានហ៊ុ សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៥

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

១៣៧.១៥០៦.៦៦០

លេខ: ៧៦០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៧៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ល្បឿនសម្រាប់យានជំនិះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

# សម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ល្បឿនបើកបរអតិបរមាសម្រាប់យានជំនិះគ្រប់ប្រភេទ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅះ

- រក្សាសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- ទប់ស្កាត់ការបើកបរយានជំនិះហួសល្បឿនកំណត់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក
- លើកកម្ពស់ការយល់ដឹង និងការចូលរួមពីគ្រប់មជ្ឈដ្ឋាន ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការធ្វើចរាចរណ៍យានជំនិះគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

វាក្យស័ព្ទដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោមះ

- **ទីប្រជុំជន** សំដៅដល់ទីកន្លែងដែលមានអគារ ឬ គេហដ្ឋានសង់ជិតៗគ្នា ហើយផ្លូវចេញ ឬ ចូលនៅទីនោះមានដាក់ផ្លាកសញ្ញាប្រាប់ទីប្រជុំជន ឈ្មោះទីប្រជុំជនសម្គាល់ការចូល ឬ ឈ្មោះទីប្រជុំជនដែលមានគំនូសបន្ទាត់ទ្រូងពណ៌ក្រហមសម្គាល់ការចេញពីទីប្រជុំជនតាមដងផ្លូវ និងមានមនុស្សធ្វើចរាចរណ៍ឆ្លងកាត់ទៅមកច្រើន
- **រថយន្តធុនស្រាល** សំដៅដល់រថយន្តដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ៣,៥ (បីក្បៀសប្រាំ)តោន
- **រថយន្តដឹកទំនិញធុនធ្ងន់** សំដៅដល់រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥(បីក្បៀសប្រាំ)តោន
- **យានយន្តកសិកម្មកែច្នៃ** សំដៅដល់យានយន្តបករណ៍កែច្នៃសម្រាប់បំពេញការងារកសិកម្ម ដូចជាយានយន្តច្រូតស្រូវ យានយន្តបោកបែនស្រូវ និងយានយន្តកិនស្រូវជាអាទិ៍

– **យានយន្តុបករណ៍** សំដៅដល់យានយន្តពិសេសដែលមានឧបករណ៍គ្រឿងចក្របំពាក់បន្ថែម គ្មានផ្ទុកមនុស្ស ឬ គ្មានផ្ទុកទំនិញនៅក្រៅកាប៊ីន ។ យានយន្តុបករណ៍មានពីរប្រភេទ៖

**ប្រភេទទី១** យានយន្តុបករណ៍ដែលមានល្បឿនអតិបរមាត្រឹម ៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោងដូចជាត្រាក់ទ័រ គ្រឿងចក្រសម្រាប់សាងសង់ផ្លូវ ស្ពានជាអាទិ៍។

**ប្រភេទទី២** យានយន្តុបករណ៍ដែលមានល្បឿនអតិបរមាលើស ៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង ដូចជា រថយន្តលាយស៊ីម៉ងត៍ រថយន្តបូមល្បាយបេតុង រថយន្ត ស្ទូច ជាអាទិ៍។

## ជំពូកទី២
## ការកំណត់ល្បឿនសម្រាប់យានជំនិះ

**មាត្រា៥.-**

លក្ខខណ្ឌសម្រាប់បើកបរយានជំនិះនៅតាមផ្លូវថ្នល់ មានដូចខាងក្រោម៖

១-អ្នកបើកបរត្រូវប្រើប្រាស់ល្បឿនស្របតាមផ្លាកសញ្ញាកំណត់ល្បឿនអតិបរមានៅតាមដងផ្លូវ។

២-នៅកន្លែងដែលពុំមានផ្លាកសញ្ញាកំណត់ល្បឿន អ្នកបើកបរត្រូវប្រើប្រាស់ល្បឿនអតិបរមាដូចខាងក្រោម៖

ក- នៅក្នុងទីប្រជុំជនល្បឿនអតិបរមា ត្រូវកំណត់ត្រឹម៖

- ៣០(សាមសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ទោចក្រយានយន្ត ទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក ត្រីចក្រយានយន្ត ត្រាក់ទ័រ យានយន្តកសិកម្ម និងសម្រាប់យានយន្តុបករណ៍ដែលមានល្បឿនអតិបរមាត្រឹម ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង
- ៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង សម្រាប់រថយន្តគ្រប់ប្រភេទ និងសម្រាប់យានយន្តុបករណ៍ដែលមានល្បឿនអតិបរមាលើស ៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង។

ខ- នៅក្រៅទីប្រជុំជនល្បឿនអតិបរមា ត្រូវកំណត់ត្រឹម៖

- ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ត្រីចក្រយានយន្ត ទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក ត្រាក់ទ័រ យានយន្តកសិកម្ម និងយានយន្តុបករណ៍ដែលមានល្បឿនអតិបរមាត្រឹម ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង
- ៦០(ហុកសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ទោចក្រយានយន្ត ដែលមានទំហំស៊ីឡាំងមិនលើសពី ១២៥(មួយរយម្ភៃប្រាំ)សង់ទីម៉ែត្រគូប យានយន្តុបករណ៍ដែលមានល្បឿនអតិបរមាលើស ៤០(សែសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង រថយន្តសណ្ដោងរ៉ឺម៉ក ឬ សឺមីរ៉ឺម៉ក និងរថយន្តដឹកកុងតែន័រគ្រប់ប្រភេទ

- ៧០(ចិតសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងលើសពី ១២៥(មួយរយម្ភៃប្រាំ)សង់ទីម៉ែត្រគូប និងរថយន្តដឹកទំនិញធុនធ្ងន់
- ៨០(ប៉ែតសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់រថយន្តធុនស្រាល និងរថយន្តដឹកអ្នកដំណើរ
- ៩០(កៅសិប)គីឡូម៉ែត្រ ក្នុងមួយម៉ោង សម្រាប់រថយន្តធុនស្រាល និងរថយន្តដឹកអ្នកដំណើរបើកបរនៅលើផ្លូវដែលមានខឿនបែងចែកទិសចរាចរណ៍ជាពីរ ហើយមានគន្លងផ្លូវចាប់ពីបួនឡើងទៅ។

បទប្បញ្ញត្តិដែលមានចែងក្នុងចំណុចទី១ និងចំណុចទី២ នៃមាត្រានេះ មិនអនុវត្តចំពោះអ្នកបើកបរយានយន្តក្បួននគរបាល យោធា កងរាជអាវុធហត្ថ គណៈប្រតិភូ ថ្នាក់ដឹកនាំជាន់ខ្ពស់ យានយន្តពន្លត់អគ្គិភ័យ យានយន្តសង្គ្រោះរបស់មន្ទីរពេទ្យ និងយានខ្លះទៀតដែលមានការអនុញ្ញាតឲ្យបន្លឺសូរសព្ទ ភ្លើងសញ្ញាពិសេស នៅពេលកំពុងបំពេញភារកិច្ចឡើយ។

**មាត្រា៦.-**

អ្នកបើកបរត្រូវគ្រប់គ្រងលើល្បឿនបើកបររបស់ខ្លួនជានិច្ច ហើយត្រូវបើកបរក្នុងល្បឿនសមស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីអាចបញ្ឈប់យានជំនិះបានទាន់ពេលវេលា និងដោយគ្មានគ្រោះថ្នាក់។

អ្នកបើកបរត្រូវបន្ថយល្បឿន ក្នុងករណីដូចខាងក្រោម៖

- ក្នុងគ្រប់ករណីដែលមានផ្លាកសញ្ញាឲ្យបន្ថយល្បឿន ឬ ផ្លាកសញ្ញាគ្រោះថ្នាក់
- ពេលមានមនុស្ស ឬ រទេះជនពិការឆ្លងកាត់ផ្លូវ
- ពេលជៀសគ្នាលើផ្លូវចង្អៀត
- ពេលជៀសរថយន្តដឹកជញ្ជូនអ្នកដំណើរ ឬ រថយន្តដឹកជញ្ជូនកុមារ ដែលកំពុងឈប់ដាក់អ្នកដំណើរ ឬ កុមារឡើងចុះ
- ពេលជៀស ឬ ជែងក្បួនយានកំពុងឈប់ ឬ នៅពេលជៀស ឬ ជែងក្បួនដង្ហែផ្សេងៗ
- ពេលទៅជិតដល់ស្ពាន ឬ ជិតដល់ផ្លូវរថភ្លើងឆ្លងកាត់
- ពេលប្តូរទិសចរាចរណ៍
- កន្លែងផ្លូវបត់ ផ្លូវកោង ផ្លូវរអិល ផ្លូវប្រសព្វ រង្វង់មូល ឬ ការដ្ឋានសាងសង់ ជួសជុលថែទាំផ្លូវ
- កន្លែងមានសាលារៀន មន្ទីរពេទ្យដែលមានទីតាំងស្ថិតនៅក្បែរផ្លូវ

- ពេលជិតដល់ទួលខ្ពស់ ឬ ពេលចុះចំណោត
- ពេលអាកាសធាតុមិនល្អដែលមិនអាចមើលឃើញបានឆ្ងាយនិងច្បាស់ល្អ
- ពេលមានវត្ថុជាឧបសគ្គ ឬ មានផ្ទះច្រើនកៀកជាប់ទ្រូងផ្លូវ
- ពេលមានយានយន្តរបស់នគរបាល យោធា កងរាជអាវុធហត្ថ គណៈប្រតិភូ ថ្នាក់ដឹកនាំជាន់ខ្ពស់ យានយន្តពន្លត់អគ្គិភ័យ យានយន្តសង្គ្រោះរបស់មន្ទីរពេទ្យ និងយានខ្លះទៀតដែលមានការអនុញ្ញាតឲ្យបន្លឺសូរសព្ទ ភ្លើងសញ្ញាពិសេស នៅពេលកំពុងបំពេញភារកិច្ច អ្នកបើកត្រូវបន្ថយល្បឿន និងបើកបរអែបទៅខាងស្តាំ បើចាំបាច់ត្រូវឈប់នៅផ្នែកខាងស្តាំបំផុតដែលអាចធ្វើទៅបាន ដើម្បីសម្រួលឲ្យយានយន្តទាំងនោះធ្វើចរាចរណ៍ដោយសុវត្ថិភាព។

**មាត្រា៧.-**

អ្នកបើកបរមិនត្រូវប្រើល្បឿនយឺតខុសប្រក្រតីដោយគ្មានមូលហេតុត្រឹមត្រូវ ដែលធ្វើឲ្យរំខានដល់យានជំនិះដទៃទៀតទេ។ អ្នកបើកបរដែលប្រើល្បឿនយឺត ត្រូវបើកបរអែបទៅខាងស្តាំ ដើម្បីទុកឲ្យអ្នកបើកបរដែលប្រើល្បឿនលឿនជែងពីខាងឆ្វេងដៃបានដោយងាយស្រួល។

អ្នកបើកបរណាដែលត្រូវបង្ខំចិត្តបន្ថយល្បឿនឲ្យយឺតខុសប្រក្រតី ត្រូវឲ្យដំណឹងដល់អ្នកបើកបរផ្សេងទៀតដោយប្រើភ្លើងសញ្ញាអាសន្ន ហើយត្រូវបើកបរអែបទៅខាងស្តាំបំផុតនៃទ្រូងផ្លូវ។

**មាត្រា៨.-**

សមត្ថកិច្ចទទួលបន្ទុកវិស័យផ្លូវថ្នល់ ត្រូវ៖

- បំពាក់ផ្លាកសញ្ញាកំណត់ល្បឿនឲ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសមស្របតាមស្ថានភាពជាក់ស្តែងរបស់ផ្លូវថ្នល់
- សហការជាមួយស្ថាប័ន ឬ អាជ្ញាធរដែនដីដែលពាក់ព័ន្ធ បំពាក់ផ្លាកសញ្ញាប្រាប់ការចូលចេញទីប្រជុំជនឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងសមស្របតាមស្ថានភាពជាក់ស្តែងរបស់ផ្លូវថ្នល់ ដែលអាចឲ្យអ្នកបើកបរមើលឃើញច្បាស់ល្អ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជាសូមហត្ថលេខា។

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ឃែរី វើលដ៍ប្រ៊ីដ ឡូជីស្ទីក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ឃែរី វើលដ៍ប្រ៊ីជ ឡូជីស្ទីក** ( **KERRY WORLDBRIDGE LOGISTICS SEZ** ) ដែលមានទីតាំងស្ថិតនៅភូមិដីណាក់សង្កែ និងភូមិព្រៃករទាំង សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ឃែរី វើលដ៍ប្រ៊ីជ ឡូជីស្ទីក** មានទំហំ ៦៣០,៤៣០ ម$^{២}$ (ប្រាំមួយរយសាមសិបពាន់បួនរយសាមសិបម៉ែត្រក្រឡា) ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ឃែរី វើលដ៍ប្រ៊ីជ ឡូជីស្ទីក** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ឃែរី វើលដ៍ប្រ៊ីជ ឡូជីស្ទីក** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងក្រុមហ៊ុន ឃែរី វើលដ៏ប្រីដ ឡូជីស្ទីក លីមីធីត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួនៗ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តាសោភា**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៨៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្ដីពី

## ការកំណត់តំបន់សហគមន៍នៃឧទ្យានជាតិព្រះសីហនុ«រាម» លើផ្ទៃដីទំហំ ៤៩០ហិកតា ស្ថិតក្នុងភូមិសារ្ស្ដ ភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់ជាតំបន់សហគមន៍នៃឧទ្យានជាតិព្រះសីហនុ«រាម» លើផ្ទៃដីទំហំ ៤៩០ហិកតា (បួនរយកៅសិបហិកតា) សម្រាប់ផ្តល់ជូនប្រជាជនដែលរស់នៅក្នុងមូលដ្ឋាន ស្ថិតនៅក្នុងភូមិសាស្ត្រ ភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានទីតាំងកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមានចំណុចគោលតាមនិយាមកាដូចខាងក្រោម៖

| No | X | Y | No | X | Y |
|---|---|---|---|---|---|
| 01 | 357283 | 1170238 | 11 | 358503 | 1169082 |
| 02 | 358563 | 1170533 | 12 | 358561 | 1169318 |
| 03 | 360732 | 1170480 | 13 | 357228 | 1169530 |
| 04 | 360657 | 1168755 | 14 | 357166 | 1169757 |
| 05 | 359876 | 1168874 | 15 | 357168 | 1169812 |
| 06 | 359863 | 1168719 | 16 | 357233 | 1169870 |
| 07 | 359100 | 1168917 | 17 | 357187 | 1169932 |
| 08 | 359064 | 1168825 | 18 | 357209 | 1170006 |
| 09 | 359047 | 1168592 | 19 | 357253 | 1170139 |
| 10 | 358654 | 1169050 | 20 | 357269 | 1170214 |

**មាត្រា២.-**

តំបន់សហគមន៍នៃឧទ្យានជាតិព្រះសីហនុ«រាម» ស្ថិតនៅក្នុងភូមិសាស្ត្រ ភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ត្រូវបានកំណត់ជាតំបន់គ្រប់គ្រងដែលបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច របស់ប្រជាជនមូលដ្ឋាន។ រាល់ការចេញប័ណ្ណសម្គាល់កម្មសិទ្ធដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល។

**មាត្រា៣.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៦១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១.-** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ចំនួន ១០គ្រឿង ជូនសប្បុរសជន ចំនួន ១០រូប ដែលបានបរិច្ចាគ ធនធានផ្ទាល់ខ្លួន ចូលរួមកសាង សមិទ្ធផលនានា នៅវត្តស្នំប្រាំពីរ ស្ថិតនៅក្នុងឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | | |
|---|---|---|---|---|
| ១- | លោក | ហោ ច័ន្ទថាន្នី | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៦០.០០០ ដុល្លារ |
| ២- | លោក | នួន ពេជ្រនិមិត្ត | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៥៩.០០០ ដុល្លារ |
| ៣- | អ្នកស្រី | ស្រ៊ុន គីមសាន | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៥៩.០០០ ដុល្លារ |
| ៤- | លោក | អ៊ីង ស៊ីមស៊ា | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៥៨.០០០ ដុល្លារ |
| ៥- | លោក | លី សំអាត | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកា ៥៦.០០០ ដុល្លារ |
| ៦- | អ្នកស្រី | គីម ស្រីពៅ | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកា ៥៥.៨០០ ដុល្លារ |
| ៧- | អ្នកស្រី | គីម ទូចគៀង | សប្បុរសជនរស់នៅប្រទេសបារាំង | ថវិកា ៥៤.៩០០ ដុល្លារ |
| ៨- | អ្នកស្រី | គីម មល្លិកា | សប្បុរសជនរស់នៅប្រទេសបារាំង | ថវិកា ៥៤.៤០០ ដុល្លារ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | | |
|---|---|---|---|---|
| ១- | អ្នកស្រី | ណាំង ណាវី | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកា ៣០.០០០ ដុល្លារ |
| ២- | អ្នកស្រី | ផាន់ ណា | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកា ៣០.០០០ ដុល្លារ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកំពត និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ.....៧៤១អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.**. បំពាក់ **មេដាយប្រាក់ស្ថាបនាជាតិ** ចំនួន ១១គ្រឿង ជូនសប្បុរសជន ចំនួន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាង សមិទ្ធផលនានា នៅវត្តស្នំប្រាំពីរ ស្ថិតនៅក្នុងឃុំម៉ាក់ប្រាង្គ ស្រុកទឹកឈូ ខេត្តកំពត កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | ឧបាសិកា | **ម៉ែន សាវ៉ាន** | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៦.៩០០ ដុល្លារ |
| ២- | លោកអាចារ្យ | **ឡុច លន់** | សប្បុរសជន នៅខេត្តកំពត | ថវិកា ៦.០០០ ដុល្លារ |
| ៣- | ឧបាសិកា | **ប៉ុល លីន** | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៥៩.០០០ ដុល្លារ |
| ៤- | អ្នកស្រី | **ស៊ុន សុខន** | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៥.៩០០ ដុល្លារ |
| ៥- | ឧបាសិកា | **តែ សុម៉ាលី** | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៥.៩០០ ដុល្លារ |
| ៦- | ឧបាសិកា | **អ៊ុំ ឈីវឆាយ** | សប្បុរសជននៅខេត្តកំពត | ថវិកា ៥.៨៩០ ដុល្លារ |
| ៧- | ឧបាសិកា | **គុយ នាច** | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៥.៨៩០ ដុល្លារ |
| ៨- | អ្នកស្រី | **ឡោ រ៉ាស៊ី** | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកា ៥.៨៩០ ដុល្លារ |
| ៩- | ឧបាសិកា | **អ៊ុក ស៊ីនួន** | សប្បុរសជន នៅរាជធានីភ្នំពេញ | ថវិកា ៥.៨៨០ ដុល្លារ |
| ១០- | ឧបាសិកា | **អ៊ុំ ចាន់** | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកា ៥.៨០០ ដុល្លារ |
| ១១- | ឧបាសិកា | **ចំនួ សុម៉ាលី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា ៥.៨០០ ដុល្លារ |

**មាត្រា ២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកំពត និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧១៣ .អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **មៀច សុរិទ្ធិភារុជាទីត** អត្តលេខ ៧៣៤៦៨ ពីអនុប្រធាននាយកដ្ឋាននគរបាលព្រំដែនទឹក ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ។

**មាត្រា ២** : បទប្បញ្ញត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧១៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

# ការតែងតាំងមន្ត្រីរាជការ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ព្រះរាជក្រឹត្យលេខនស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងជាអគ្គនាយករង អគ្គនាយិការង អគ្គាធិការរង អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន អធិការ និងជំនួយការអមក្រសួងបរិស្ថាន ចំនួន៧៥រូប ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១ | លោក | ម៉េង សារុជ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ២ | លោក | ហេង ភារិទ្ធ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣ | លោក | កែ វង្សវឌ្ឍនា | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៤ | លោក | អេង គឹមសាន | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៥ | លោក | ឯ វុឌ្ឍី | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៦ | លោក | តាំង វណ្ណថា | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៧ | លោក | ឃិន សំភាយ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៨ | លោក | ជ្រិន សុខា | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៩ | លោក | ឡុង រិទ្ធីរក្ស | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ១០ | លោក | កុច សុវ៉ាទ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ១១ | លោក | ស៊ុម សុខម្ធ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ១២ | លោក | មាស សុផល | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ១៣ | លោក | គឹម ណុង | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ១៤ | លោក | អ៊ុក ណាវ៉ាន់ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ១៥ | លោក | សេង សោព | ជារត្តនាយករង នៃរត្តនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ១៦ | លោក | ហែម សុចិត្ត | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ១៧ | លោក | សុខខេង នរិទ្ធ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ១៨ | លោក | ស៊ី ប៉ាមុនី | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ១៩ | លោកស្រី | ឃួន ធារី | ជាអគ្គនាយិការង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ២០ | លោក | ឈុន វណ្ណៈ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន |
| ២១ | លោក | ងួន គង់ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន |
| ២២ | លោក | រាត់ សុិទ្ធ | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន |
| ២៣ | លោកស្រី | ង៉ិន លីណា | ជាអគ្គនាយិការងនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន |
| ២៤ | លោក | ទេព ប៊ុននី | ជាអគ្គាធិការរង |
| ២៥ | លោក | ឈុន ប៊ុនលី | ជាអគ្គាធិការរង |
| ២៦ | លោក | អៀង សុវណ្ណនរ៉ា | ជាអគ្គាធិការរង |
| ២៧ | លោក | ទឹម ម៉ានី | ជាអគ្គាធិការរង |

| | | |
|---|---|---|
| ២៨ | លោក នួន វដ្ឋា | ជាអគ្គាធិការរង |
| ២៩ | លោក ម៉ឺន មករា | ជាអគ្គាធិការរង |
| ៣០ | លោក នៅ សំណាង | ជាជំនួយការអមក្រសួង មានឋានៈស្មើ អគ្គនាយករង |
| ៣១ | លោក សេក ធា | ជាប្រធាននាយកដ្ឋានរដ្ឋបាល<br>នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣២ | លោក ខឹម សុវណ្ណា | ជាប្រធាននាយកដ្ឋានធនធានមនុស្ស<br>នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣៣ | លោក ទេស សំណាង | ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងគណនេយ្យ<br>នៃអគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣៤ | លោក គុជ កុសល | ជាប្រធាននាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ<br>នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣៥ | លោក ហ៊ី ម៉ារ៉ា | ជាប្រធាននាយកដ្ឋានផែនការ និងថវិកា<br>នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣៦ | លោក ប៉ាន់ បូណុច | ជាប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ<br>នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៣៧ | លោក ប៉ាក សុខារ៉ាវុត | ជាប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង<br>នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៣៨ | លោក ពុទ្ធ សូរិទ្ធី | ជាប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពទឹក<br>នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៣៩ | លោក ឌី គីដែន | ជាប្រធាននាយកដ្ឋានគ្រប់គ្រងសំណល់រឹង<br>នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៤០ | លោក ថុល ចាន់ថន | ជាប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់<br>នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៤១ | លោក ជា ស៊ីណា | ជាប្រធាននាយកដ្ឋានអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់<br>នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៤២ | លោក ដាញ់ សេរី | ជាប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន<br>នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៤៣ | លោកស្រី មាស ច័ន្ទធីតា | ជាប្រធានមន្ទីរពិសោធន៍ នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ៤៤ | កញ្ញា លី សុភ័ណ្ឌ | ជាប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ<br>នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ៤៥ | លោក គង់ គីមស្រេង | ជាប្រធាននាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោក<br>នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ៤៦ | លោក ហុង តារ៉ាវុធ | ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍តំបន់ការពារធម្មជាតិ<br>នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ៤៧ | លោក នេត នាថ | ជាប្រធាននាយកដ្ឋានតំបន់បេតិកភណ្ឌ<br>នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |

| | | | |
|---|---|---|---|
| ៤៨ | លោក | ឃិន ម៉េងឃាង | ជាប្រធាននាយកដ្ឋានសហគមន៍តំបន់ការពារធម្មជាតិ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ៤៩ | លោក | ស្រី ស៊ុនលាង | ជាប្រធាននាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ៥០ | លោក | ថៃ ចន្ថា | ជាប្រធាននាយកដ្ឋានអភិរក្សសមុទ្រ និងតំបន់ឆ្នេរ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ៥១ | លោក | ញ៉ិល ធន | ជាប្រធាននាយកដ្ឋានអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| ៥២ | លោក | វន់ វណ្ណារិទ្ធ | ជាប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន |
| ៥៣ | លោក | ទូច វីណា | ជាប្រធាននាយកដ្ឋានសេវាព័ត៌មានភូមិសាស្ត្រ នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន |
| ៥៤ | លោក | សែម ស៊ុនដារ៉ា | ជាប្រធាននាយកដ្ឋានអប់រំបរិស្ថាន នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន |
| ៥៥ | លោក | សែម សុភ័ក្រ | ជាប្រធាននាយកដ្ឋានព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន |
| ៥៦ | កញ្ញា | គឹម ណេង | ជាប្រធាននាយកដ្ឋានរង្វាន់ និងលើកទឹកចិត្ត នៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន |
| ៥៧ | លោក | ម៉ា ច័ន្ទសុទ្ធា | ជាប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ៥៨ | លោក | ស៊ុំ ធី | ជាប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ៥៩ | លោក | តាំង ម៉េងអៀង | ជាប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ៦០ | លោក | ជា ចន្ទន៍ធូ | ជាប្រធាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ៦១ | លោក | ម៉េង មុនីរក្ស | ជាប្រធាននាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ៦២ | លោក | ហាវ សោភា | ជាអធិការ |
| ៦៣ | លោក | ហាក់ ចាន់នី | ជាអធិការ |
| ៦៤ | លោក | ខឹម ប៊ុនហេង | ជាអធិការ |
| ៦៥ | លោក | ណុប ហាក់ | ជាអធិការ |
| ៦៦ | លោក | ម៉ម សុវណ្ណ | ជាអធិការ |
| ៦៧ | លោក | បាន សុវណ្ណា | ជាអធិការ |

| | | | |
|---|---|---|---|
| ៦៨ | លោក | ស៊ឹម សុធី | ជាអធិការ |
| ៦៩ | លោក | ជុំ សុខជា | ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៧០ | លោក | ឈា មារិត | ជាជំនួយការអមក្រសួង មានឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៧១ | លោក | ជួន ច័ន្ទរិទ្ធី | ជាជំនួយការអមក្រសួង មានឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៧២ | លោក | ណុប ចន្ទី | ជាជំនួយការអមក្រសួង មានឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៧៣ | លោក | ស្រី ម៉ារ៉ូណា | ជាជំនួយការអមក្រសួង មានឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៧៤ | លោក | សំ ជា | ជាជំនួយការអមក្រសួង មានឋានៈស្មើ ប្រធាននាយកដ្ឋាន |
| ៧៥ | លោក | សុខ វង់ | ជាជំនួយការអមក្រសួង មានឋានៈស្មើ ប្រធាននាយកដ្ឋាន |

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧៤១៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ . បក  ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១ :**

តែងតាំងមន្ត្រីរាជការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន ០៥ រូប ជា **ប្រធាននាយកដ្ឋាន** ដូចមានរាយនាមខាងក្រោម:

១. លោក **នេត សេរី** ជាប្រធាននាយកដ្ឋាន**រដ្ឋបាល**
២. លោក **ចាន់ រតនា** ជាប្រធាននាយកដ្ឋាន**អង្គការអន្តរជាតិ**
៣. លោក **ចេង ម៉ានិត** ជាប្រធាននាយកដ្ឋាន**សហប្រតិបត្តិការអន្តរជាតិ**
៤. លោក **ខួន សុខចេង** ជាប្រធាននាយកដ្ឋាន**អាស៊ីទី១**
៥. លោកស្រី **រត្ន ម៉ានី** ជាប្រធាននាយកដ្ឋាន**សហប្រតិបត្តិការមេគង្គ**។

**មាត្រា ២ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម **សោម សឿន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១:** តែងតាំងលោក **សោម លីន** ជាជំនួយការឯកឧត្តម **សោម សឿន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន ជំនួសលោក **ចាន់ សុខសាន្ត** ដែលទទួលភារកិច្ចថ្មី ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៧១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ

## សម្រេច

**មាត្រា ១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ** ចំនួន ១៥គ្រឿង ជូនមន្ត្រីរាជការនៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តត្បូងឃ្មុំ ចំនួន ១៥រូប ដែលមានស្នាដៃល្អ ក្នុងការកសាងអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធខេត្តត្បូងឃ្មុំ កន្លងមក ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

១. លោក **ពេញវង្ស វិចិត្រា** ប្រធានការិយាល័យមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

២. លោក **ផេង ច័ន្ទឆាយា** ប្រធានការិយាល័យមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

៣. លោក **ចាតសាន្ត សុន្ទរ៉ា** ប្រធានអង្គភាពមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

៤. លោក **ជាង ប៉ាក់ណា** អនុប្រធានអង្គភាពមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

៥. លោក **ស្រេង លឹមគុជ** អនុប្រធានការិយាល័យមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

៦. លោក **ស្រ៊ុន សារក្ស** អនុប្រធានអង្គភាពមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

៧. លោក **គិន សុវណ្ណ** អនុប្រធានអង្គភាពមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

៨. លោក **សូ ឡូញ** ប្រធានសេវាដ្ឋានមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

៩. លោក **វណ្ណា ស៊ាងឃី** ប្រធានអង្គភាពមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

១០. លោក **ខាន់ ស្មៀន** ប្រធានអង្គភាពមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

១១. លោក **អ៊ឹម ផាន** អនុប្រធានអង្គភាពមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

១២. លោក **ស្ងួខ ស៊ីហាន** ប្រធានការិយាល័យស្រុកមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

១៣. លោក **សឿ ស៊ីធឿន** ប្រធានការិយាល័យស្រុកមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

១៤. លោក **សេក យុ** ប្រធានការិយាល័យស្រុកមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត

១៥. លោក **ទឹម សុផល** អនុប្រធានការិយាល័យក្រុងមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត

**មាត្រា ២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧៧.១៨ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ៤១ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងអប់រំ នៅ**វត្តសុវណ្ណសត្ថារាម** (ហៅវត្តផ្លូវមាន់) ស្ថិតនៅក្នុងឃុំស្នាមព្រះ **នៅវត្តពោធិ៍អណ្តែត** (ហៅវត្តព្រះចំបក់ )ស្ថិតនៅក្នុងឃុំត្រពាំងជង ស្រុកបាកាន និងក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ២៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណសាសនវរោ **ចន្ទ សន** ព្រះចៅអធិការវត្តសុវណ្ណសត្ថារាម បច្ច័យចំនួន ១១.៨៨០ ដុល្លារ

| | | | | |
|---|---|---|---|---|
| ២-លោក | **ប៉េ** | **ជីងតុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៤០.០០០ ដុល្លារ |
| ៣-លោក | **ប៉េ** | **គីមហុង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៤០.០០០ ដុល្លារ |
| ៤-លោក | **ស៊ុង** | **ហាក់ហួត** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៩.២០០ ដុល្លារ |
| ៥-ឧបាសក | **ប៉េ** | **សុងលៀក** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៧.៥០០ ដុល្លារ |
| ៦-ឧបាសិកា | **ខូច** | **ហ៊ុយខេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១៧.៣១៨ ដុល្លារ |

៧-ឯកឧត្តម **ណុះ  ស្លេះ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ថវិកាចំនួន ១៥.០០០ ដុល្លារ

៨-លោក **លី  ចន្ថា** នាយខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ថវិកាចំនួន ១៤.០០០ ដុល្លារ

៩-ឧបាសិកា **តាំង  សុខហ៊ុយ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៣.០០០ ដុល្លារ

១០-លោក **ឈាន  ដារ៉ា** ប្រធានម៉ៅការសំណង់ ថវិកាចំនួន ១២.០០០ ដុល្លារ

១១-លោក **ឡាច  ផេងលី** ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ថវិកាចំនួន ១២.០០០ ដុល្លារ

១២-លោក **សួង  សុភី** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ថវិកាចំនួន ១២.០០០ ដុល្លារ

១៣-លោក **ថន  សុតារុណ** អនុប្រធានសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ១២.០០០ ដុល្លារ

១៤-លោក **លី  សុវណ្ណារិទ្ធ** ប្រធានសម្របសម្រួលនៃសមាគមអតីតសិស្សខេត្តពោធិ៍សាត់
ថវិកាចំនួន ១២.០០០ ដុល្លារ

១៥-លោក **គន  សខ្វាត់** ទីប្រឹក្សាសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ១២.០០០ ដុល្លារ

១៦-លោក **ធឿន  ឡាំចាដា** ប្រធានរដ្ឋបាលសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ១១.៥០០ ដុល្លារ

១៧-លោកស្រី **អ៊ុម  រម្យថា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១១.៥០០ ដុល្លារ

១៨-លោក **ល្អតច័ន  សុធាបុត្ត** អនុប្រធានរដ្ឋបាលសមាគមអតីតសិស្សខេត្តពោធិ៍សាត់
ថវិកាចំនួន ១១.០០០ ដុល្លារ

១៩-លោក **លឹម  ឧទ្ធី** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ថវិកាចំនួន ១១.០០០ ដុល្លារ

២០-លោក **អឿង  លីមសេង** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១១.០០០ ដុល្លារ

២១-លោក **ប៊ុន  ធី** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១០.១០០ ដុល្លារ

២២-ឧបាសិកា **យូ  ឆេង** សប្បុរសជននៅខេត្តកំពង់ស្ពឺ ថវិកាចំនួន ១០.០០០ ដុល្លារ

២៣-លោកស្រី **ថៃ  គា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

២៤-លោក **ញៀម  អេង** អាចារ្យវត្តព្រះចំបក់ ថវិកាចំនួន ១០.០០០ ដុល្លារ

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៩ គ្រឿង ផ្តល់ជូន :**

១-លោក **អាំង  ចិ** នាយកវិទ្យាល័យពោធិ៍សាត់ ថវិកាចំនួន ៧.៧០០ ដុល្លារ

២-លោក **អាំង  តាក់មុនី** នាយករងវិទ្យាល័យពោធិ៍សាត់ ថវិកាចំនួន ៧.១០០ ដុល្លារ

៣-លោក **ជិន  ផល្លា** នាយករងវិទ្យាល័យពោធិ៍សាត់ ថវិកាចំនួន ៧.០៥០ ដុល្លារ

៤-លោក **អ៊ុន  សៀវទើង** អនុប្រធានរដ្ឋបាលសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ៧.០០០ ដុល្លារ

៥-កញ្ញា **ភួង  ច័ន្ទនិច** ប្រធានផ្នែកអប់រំ នៃសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ៧.០០០ ដុល្លារ

៦-កញ្ញា **កែវ  សិរីបញ្ញា** សប្បុរសជននៅខេត្តពោធិ៍សាត់ ថវិកាចំនួន ៧.០០០ ដុល្លារ

៧-កញ្ញា **ស៊ីណា  ឡៃន** ជំនួយការប្រធានសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ៦.៦០០ ដុល្លារ

៨-លោក **យ៉ត  នីសុភ័ក្រ្ត** ជំនួយការប្រធានសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ៦.៥០០ ដុល្លារ

៩-លោក **យ៉េម  តិរុណ** ប្រធានបច្ចេកទេស នៃសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ៦.០០០ ដុល្លារ

**គ. មេដាយសិរីវឌ្ឍនជាតិចំនួន ០៨ គ្រឿង ផ្តល់ជូន :**

១-លោក **ស៊ិន ចំនួតារា** សមាជិកសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ៣.០០០ ដុល្លារ

២-លោក **លី ចំនួរស្មី** ក្រុមបច្ចេកទេស នៃសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ៣.០០០ ដុល្លារ

៣-លោក **ឡេង ទាសនា** សមាជិកសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ៣.០០០ ដុល្លារ

៤-លោក **ខឹន បញ្ញាច័ន្ទ** ប្រធានផ្នែកទំនាក់ទំនង នៃសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ២.០០០ ដុល្លារ

៥-លោក **ថាន់ ពិទូរ្យ** សមាជិកសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ២.០០០ ដុល្លារ

៦-លោក **គាំ កាន់ទាចា** សមាជិកសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ២.០០០ ដុល្លារ

៧-កញ្ញា **ម៉ន ចំម៉ាពេជ្រ** សមាជិកសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ២.០០០ ដុល្លារ

៨-កញ្ញា **ទន្ស្សី គណភិការ** សមាជិកសមាគមអតីតសិស្សខេត្តពោធិ៍សាត់ ថវិកាចំនួន ២.០០០ ដុល្លារ

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ...១៨៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសសុវត្ថារា** ថ្នាក់**ធិបឌិន្ទ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា និងអប់រំ នៅ**វត្តសុវណ្ណសត្ថារាម** (ហៅវត្តផ្លូវមាន់)ស្ថិតនៅក្នុងឃុំស្នាមព្រះ **នៅវត្តពោធិ៍អណ្តែត**(ហៅវត្តព្រះចំបក់ )ស្ថិតនៅក្នុងឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | |
|---|---|---|
| ១-ព្រះតេជគុណ **ឡាយ ភន** | ព្រះចៅអធិការវត្តបាកាន | បច្ច័យចំនួន ៤០.០០០ ដុល្លារ |
| ២-លោក **ឈឿន សារិទ្ធ** | មេបញ្ជាការរងយោធភូមិភាគ៥ | ថវិកាចំនួន ៤០.០០០ ដុល្លារ |
| ៣-ឧបាសិកា **ឆាំង សុខលីម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៤០.០០០ ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៨៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ២២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សាលាធម្មសភា ០១ខ្នង មានបណ្តោយ ២៤ម៉ែត្រ និងទទឹង ២១ម៉ែត្រ និងកុដិ នៅ **វត្តភ្នំព្រះទេវៈ** ស្ថិតនៅក្នុងឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៥ គ្រឿង ផ្តល់ជូន :**

| | | |
|---|---|---|
| ១-ឧកញ៉ា **ម៉ុន ធី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ២០.០០០ ដុល្លារ |
| ២-ឧបាសក **អុក យ៉េត** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ២០.០០០ ដុល្លារ |
| ៣-ឧបាសិកា **ចាន់ ឈុករ័ត្ន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ២០.០០០ ដុល្លារ |
| ៤-ឧបាសក **ជួប ម៉ូត** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ២០.០០០ ដុល្លារ |
| ៥-លោកស្រី **អ៊ុន សាលី** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ២០.០០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៦ គ្រឿង ប្រគេន និងផ្តល់ជូន :**

| | | |
|---|---|---|
| ១-ព្រះតេជគុណ **អ៊ិន ឃ្លី** | ព្រះគ្រូសូត្រស្តាំវត្តភ្នំព្រះទេវៈ | បច្ច័យចំនួន ៥.០០០ ដុល្លារ |
| ២-ព្រះតេជគុណ **ចម ចាន់** | ព្រះគ្រូសូត្រឆ្វេងវត្តភ្នំព្រះទេវៈ | បច្ច័យចំនួន ៥.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៣-ឧបាសក **តឿក សាឃឿន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៥.០០០ ដុល្លារ |
| ៤-ឧបាសក **គង់ អួន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៥.០០០ ដុល្លារ |
| ៥-ឧបាសិកា **ប៉ុក សំអាន** | គណៈកម្មការវត្តភ្នំព្រះទេវៈ | ថវិកាចំនួន | ៥.០០០ ដុល្លារ |
| ៦-លោកស្រី **មិត្ត មុំ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ៥.០០០ ដុល្លារ |

**គ. មេដាយសិរីវឌ្ឍិស្ថាបនាជាតិចំនួន ១១ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ឧបាសក **នែម អ៊ាន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ២-ឧបាសក **គីម គីស** | គណៈកម្មការវត្តភ្នំព្រះទេវៈ | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៣-ឧបាសក **ម៉ាញ ហោម** | គណៈកម្មការវត្តភ្នំព្រះទេវៈ | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៤-ឧបាសិកា **ព្រះ ខាត់ណា** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៥-ឧបាសក **សំ ប៉ុក** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៦-ឧបាសក **គ្រប់ សឿម** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៧-លោក **សួរ សុន** | អភិបាលស្រុកបន្ទាយស្រី | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៨-លោក **អ៊ុំ អ៊ុំង** | មេឃុំរំចេក | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៩-ឧបាសក **ម៉ៅ មុត** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ១០-ឧបាសិកា **និត្យ សម្បត្តិ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ១១-ឧបាសិកា **លួន ខុម** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន | ១.០០០ ដុល្លារ |

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧៧១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** បំពាក់**មេដាយមាសការងារ** ជូនគណៈកម្មការវត្តពោធិ៍ក្នុង ដែលបានខិតខំអំពាវនាវសប្បុរសជននានា ជួយកសាងសមិទ្ធផលផ្សេងៗ នៅក្នុងវត្តពោធិ៍ក្នុង ស្ថិតក្នុងភូមិរតនៈ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១-លោក | **ជា** | **ផាត** | អនុប្រធានគណៈកម្មការវត្តពោធិ៍ក្នុង |
| ២-លោក | **អ៊ឹម** | **ស៊ីផាត់** | សមាជិកគណៈកម្មការវត្តពោធិ៍ក្នុង |
| ៣-លោក | **លីវ** | **ឆុន** | សមាជិកគណៈកម្មការវត្តពោធិ៍ក្នុង |
| ៤-លោក | **លី** | **ឈន** | សមាជិកគណៈកម្មការវត្តពោធិ៍ក្នុង |
| ៥-លោក | **គឹម** | **វ៉ាន់** | សមាជិកគណៈកម្មការវត្តពោធិ៍ក្នុង |
| ៦-លោក | **ជុក** | **ជួម** | សមាជិកគណៈកម្មការវត្តពោធិ៍ក្នុង ។ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលេក្ខណសម្បត្តិវរៈជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា ១.**- បំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីអាជ្ញាធរជាតិព្រះវិហារ ចំនួន ៣៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមាសការងារ

| | | | |
|---|---|---|---|
| ១- | លោក | ចិន ចំរើន | មន្ត្រី |
| ២- | លោក | យាន ស៊ុន្ដារ៉ាត | មន្ត្រី |
| ៣- | លោក | ម៉ុំ លាភពិសិដ្ឋ | មន្ត្រី |
| ៤- | លោក | ហួត ហៃ | មន្ត្រី |
| ៥- | លោក | ឌុំ តិរម្យ | មន្ត្រី |
| ៦- | លោក | សូ ធៀម | មន្ត្រី |
| ៧- | លោក | ឃុន សុតំរ្គ | មន្ត្រី |
| ៨- | លោក | សេខ ចៅចិត្រ | មន្ត្រី |
| ៩- | លោក | ម៉ក់ ឡឿង | មន្ត្រី |

ខ-មេដាយប្រាក់ការងារ

| | | | |
|---|---|---|---|
| ១- | លោក | ហ៊ីម សុម៉េត | មន្ត្រី |
| ២- | លោក | ហ៊ាង សារិត | មន្ត្រី |
| ៣- | លោកស្រី | ជា សុខេង | មន្ត្រី |
| ៤- | លោក | ឆួប សៅវឌ្ឍនា | មន្ត្រី |
| ៥- | លោកស្រី | គីម រតនៈ | មន្ត្រី |

| | | | |
|---|---|---|---|
| ៦- | លោកស្រី | អ៊ា ម៉ារី | មន្ត្រី |
| ៧- | លោកស្រី | ទ៊ាន់ ណារី | មន្ត្រី |
| ៨- | លោកស្រី | ម៉ក់ គៀនសេង | មន្ត្រី |
| ៩- | លោក | ណាត មីនា | មន្ត្រី |
| ១០- | លោក | មិន ចាន់ថា | មន្ត្រី |
| ១១- | លោក | មើន សីហា | មន្ត្រី |
| ១២- | លោក | មួង ចាន់សី | មន្ត្រី |
| ១៣- | លោក | គុំ គីន | សន្តិសុខអភិរក្ស |
| ១៤- | លោក | ហ៊ុន ចន្ថា | សន្តិសុខអភិរក្ស |
| ១៥- | លោក | ដាន់ តាព | សន្តិសុខអភិរក្ស |

**គ-មេជាយស័រីទូភារទារ**

| | | | |
|---|---|---|---|
| ១- | លោក | សេង ណុន | មន្ត្រី |
| ២- | លោក | ឡៅ រ័ត្នមុនី | មន្ត្រី |
| ៣- | លោក | យឿន តាស់ | សន្តិសុខអភិរក្ស |
| ៤- | លោកស្រី | សាយ វណ្ណី | ភ្នាក់ងារទេសចរណ៍ |
| ៥- | លោកស្រី | ទ៊ា សុនីតា | ភ្នាក់ងារទេសចរណ៍ |
| ៦- | លោកស្រី | ទ៊ាន់ គីមយ៉ាន | ពលករ |
| ៧- | លោកស្រី | អ៊ុំ ថា | ពលករ |
| ៨- | លោក | ឈួយ លាង | ពលករ |
| ៩- | លោក | ឆែន ធុញ | ឆ្មាំ |
| ១០- | លោកស្រី | ទង់ សុធី | ឆ្មាំ |

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរៈជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៥១ សសរ...**

## សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវហេតុការណ៍ដែលនាំឲ្យកើតមានអំពើហឹង្សា នៅបង្គោលព្រំដែនលេខ២០៣ តំបន់ព្រំដែនកម្ពុជា-វៀតណាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## ស ម្រេ ច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវស៊ើបបញ្ជាក់ហេតុការណ៍ ដែលនាំឲ្យកើតមានអំពើហឹង្សា នៅបង្គោលព្រំដែនលេខ២០៣ (ទួលតាព្រាប) តំបន់ព្រំដែន កម្ពុជា-វៀតណាម ស្ថិតនៅភូមិធ្លកថ្មី ឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដែលមាន សមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម **ឡុង វិសាលោ** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធាន

២-ឯកឧត្តម នាយឧត្តមសេនីយ៍ **ឌុល គឿន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៣-ឯកឧត្តម នាយឧត្តមសេនីយ៍ **ឯល ម៉ាន់សារ៉ាត** រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន

៤-ឯកឧត្តម នាយឧត្តមសេនីយ៍ **សំរិទ្ធ ឌី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៥-ឯកឧត្តម **ជៀង អំ** អភិបាលខេត្តស្វាយរៀង សមាជិក

៦-ឯកឧត្តម នាយឧត្តមសេនីយ៍ **ដាំ ឧុទ្ធី** អគ្គស្នងការរងនគរបាលជាតិ សមាជិក

៧-ឯកឧត្តម **គីម ចន្ទ្បនសោភ័ណ** អគ្គនាយករងរដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក

៨-ឯកឧត្តម **ស៊ិន សុធានី** អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍អាជ្ញាធរជាតិកិច្ចការព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩-ឧត្តមសេនីយ៍ត្រី **គីង ឃន** ស្នងការនគរបាលខេត្តស្វាយរៀង សមាជិក

**ប្រការ២ .-**

គណៈកម្មការមានភារកិច្ចដូចខាងក្រោម៖

-ទំនាក់ទំនង ជាមួយភាគីវៀតណាម ដើម្បីស្រាវជ្រាវស៊ើបបញ្ជាក់ហេតុការណ៍ ដែលកើតមាននៅចំណុចបង្គោលព្រំដែន លេខ២០៣ស្ថិតនៅភូមិធ្លកថ្មី ឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

-ប្រមូលផ្តុំគ្រប់ឯកសារដែលពាក់ព័ន្ធទាំងផ្នែកច្បាប់ និងផ្នែកបច្ចេកទេសកិច្ចការខ្សែបន្ទាត់ព្រំដែនកម្ពុជា-វៀតណាម ដើម្បីជាមូលដ្ឋានក្នុងការផ្ទៀងផ្ទាត់ ពិភាក្សា និងដោះស្រាយ ។

-ចុះអង្កេតស្រាវជ្រាវជាក់ស្តែងដល់ទីកន្លែងកើតហេតុ ដើម្បីប្រមូលព័ត៌មាន វត្ថុតាង សាក្សី សម្រាប់កសាងឯកសារ ធ្វើការដោះស្រាយ ។

-ធ្វើសេចក្តីរាយការណ៍សុំយោបល់ដឹកនាំ និងការសម្រេចពីប្រមុខរាជរដ្ឋាភិបាល តាមរយៈសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមជំហ៊ានការងារនិមួយៗ ។

-ធ្វើរបាយការណ៍បូកសរុបលទ្ធផល និងផ្តើមឡើងនូវវិធានការជូនរាជរដ្ឋាភិបាលពិនិត្យ សម្រេច ។

**ប្រការ៣.-**

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបំពេញការងារ និងមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទជាជំនួយការ តាមការចាំបាច់ ។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តស្វាយរៀង គ្រប់ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រីស្តីទី**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល:</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

- អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ដូចប្រការ៤

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៣១......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិចុះហត្ថលេខា ជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុ លើអាណត្តិបើកប្រាក់ "ថាមពល និងទឹក" និង "សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍" ជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា

- បានឃើញអនុក្រឹត្យលេខ ៣៣៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩០១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០៤ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ លើលិខិតលេខ ១០២៦៦ សហវ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានប្រគល់សិទ្ធិជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ចុះហត្ថលេខា ជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុ ក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើសំណុំឯកសារអាណត្តិបើកប្រាក់ ជំពូក ៦០ គណនី ៦០០៦ " ថាមពល និងទឹក" និងជំពូក៦១ គណនី ៦១១៤ "សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍"។

**ប្រការ២.-**

ឥណទានថវិការបស់អគ្គនាយកដ្ឋានពន្ធដារ សម្រាប់ចំណាយក្នុងឆ្នាំ២០១៥ មាន÷

១) ជំពូក៦០ គណនី៦០០៦ អនុគណនី៦០០៦១ "អគ្គិសនី" មានទឹកប្រាក់ចំនួន ៣៤២ ៨៤០ ០០៥ រៀល "បីរយសែសិបពីរលាន ប្រាំបីរយសែសិបពាន់ ប្រាំរៀលគត់"

២) ជំពូក៦០ គណនី៦០០៦ អនុគណនី៦០០៦២ "ទឹក" មានទឹកប្រាក់ចំនួន ១១៦ ១៧១ ៤៦២ រៀល "មួយរយដប់ប្រាំមួយលាន មួយរយចិតសិបមួយពាន់ បួនរយហុកសិបពីររៀលគត់"

៣) ជំពូក៦១ គណនី៦១១៤ អនុគណនី៦១១៤១ "សោហ៊ុយប្រៃសណីយ៍" មានទឹកប្រាក់ចំនួន ១៦៩ ៧០០ ០០០ រៀល "មួយរយហុកសិបប្រាំបួនលាន ប្រាំពីររយពាន់រៀលគត់"

៤) ជំពូក៦១ គណនី៦១១៤ អនុគណនី៦១១៤២ "សោហ៊ុយទូរគមនាគមន៍" មានទឹកប្រាក់ចំនួន ២១៤ ៦៩៨ ០៤៧ រៀល "ពីររយដប់បួនលាន ប្រាំមួយរយកៅសិបប្រាំបីពាន់ សែសិបប្រាំពីររៀលគត់"

ឥណទាននេះត្រូវបែងចែកតាម ចង្កោមសកម្មភាព និងសកម្មភាព (ក្រុម ប្រភេទ ជំពូក គណនី និង អនុគណនី) ដូចមានក្នុងសៀវភៅចវិកាកម្មវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៦៣៦...សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិ និងអភិបាលហិរញ្ញវត្ថុ លើអាណត្តិបើកប្រាក់ "ថាមពល និងទឹក" និង "សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍" ជូនឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា

- បានឃើញអនុក្រឹត្យលេខ ៣៣៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំនិងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩០១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ ១៩០៤ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ លើលិខិតលេខ ១០២៦៦ សហវ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានប្រគល់សិទ្ធិជូនឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាអាណាប័កផ្ទេរសិទ្ធិនិងអភិបាលហិរញ្ញវត្ថុ សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុ នៃថវិការបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើសំណុំឯកសារអាណត្តិបើកប្រាក់ ជំពូក ៦០ គណនី ៦០០៦ " ថាមពល និងទឹក" និងជំពូក៦១ គណនី ៦១១៤ "សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍"។

**ប្រការ២.-**

ឥណទានថវិការបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សម្រាប់ចំណាយក្នុងឆ្នាំ២០១៥ មាន÷

១) ជំពូក៦០ គណនី៦០០៦ អនុគណនី៦០០៦១ “អគ្គិសនី” មានទឹកប្រាក់ចំនួន ១ ០០៩ ៧៥៤ ៩០០ រៀល “មួយពាន់ប្រាំបួនលាន ប្រាំពីររយហាសិបបួនពាន់ ប្រាំបួនរយរៀលគត់”

២) ជំពូក៦០ គណនី៦០០៦ អនុគណនី៦០០៦២ “ទឹក” មានទឹកប្រាក់ចំនួន ១៩៧ ៩៨១ ៦០០ រៀល “មួយរយកៅសិបប្រាំពីរលាន ប្រាំបួនរយប៉ែតសិបមួយពាន់ ប្រាំមួយរយរៀលគត់”

៣) ជំពូក៦១ គណនី៦១១៤ អនុគណនី៦១១៤២ “សោហ៊ុយទូរគមនាគមន៍” មានទឹកប្រាក់ចំនួន ៣៩៩ ៧៣២ ៥០៩ រៀល “បីរយកៅសិបប្រាំបួនលាន ប្រាំពីររយសាមសិបពីរពាន់ ប្រាំរយប្រាំបួនរៀលគត់”។

ឥណទាននេះត្រូវបែងចែកតាមចង្កោមសកម្មភាព និងសកម្មភាព (ក្រុម ប្រភេទ ជំពូក គណនី និងអនុ-គណនី) ដូចមានក្នុងសៀវភៅថវិកាកម្មវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៣៣ សហវ.ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងរដ្ឋលេខាធិការបុរេប្រទាន របស់ក្រសួងអប់រំ យុវជន និងកីឡា នៅសាកលវិទ្យាល័យមានជ័យ

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**សាកលវិទ្យាធិការ**
**សាកលវិទ្យាល័យមានជ័យ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥

-បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

-បានឃើញប្រកាសលេខ០០៤សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-ទំព័រ១-

- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៦២ អយក.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ១:**

ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡាដូចខាងក្រោម:

**១. លោកស្រី ទេព គន្ធា** ឋានៈជា ប្រធានការិយាល័យគណនេយ្យ និងផែនការ ឱ្យទទួលបន្ទុកការងារជារជ្ជទេយ្យករបុរេប្រទាន

**២. លោកស្រី រស់ សុផានី** ឋានៈជា ប្រធានបណ្ណាល័យ ឱ្យទទួលបន្ទុកការងារជា រជ្ជទេយ្យករបុរេប្រទានរង

**ប្រការ២:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យមានជ័យ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០១៥

**សាកលវិទ្យាធិការ**
**សាកលវិទ្យាល័យមានជ័យ**

**សំ ង៉ា**

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៤១ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន
# នៅក្រសួងសាធារណការ និងដឹកជញ្ជូន

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល

- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន

**<u>សម្រេច</u>**

**<u>ប្រការ ១</u>** : ត្រូវបានតែងតាំង មន្ត្រីរាជការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ដូចខាងក្រោម៖

- លោកស្រី **ពិន ឌីណា** អនុប្រធានការិយាល័យនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុជា រជ្ជទេយ្យករបុរេប្រទាននៅ ក្រសួងសាធារណការ និងដឹកជញ្ជូន
- កញ្ញា **ស៊្រុន សុលីនដា** មន្ត្រី នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ជារជ្ជទេយ្យករបុរេប្រទានរងនៅក្រសួងសាធារណការ និងដឹកជញ្ជូន

**<u>ប្រការ ២</u>** :បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍ ។

**<u>ប្រការ ៣</u>** :នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានគ្រប់អង្គភាព នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗ ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ[illegible] ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

ត្រាំ អ៊ីវតឹក

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៦៤២...សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពីការបង្កើតរដ្ឋបេឡាឃុំប្រេងឥន្ធនៈសម្រាប់ឆ្នាំ២០១៥
# របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីកាអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន

## **សម្រេច**

**ប្រការ ១** : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ", ជំពូក៦១ "សេវាកម្ម", នៅក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។ តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ ២** : ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទានត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤** : នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

ត្រាំ អ៊ីវតឹក

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ក្រសួងសាធារណការនិងដឹកជញ្ជូន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងឧបសម្ព័ន្ធថវិកាបុរេប្រទានថវិកាកម្មវិធី ឆ្នាំ ២០១៥

## របស់ក្រសួងសាធារណការនិងដឹកជញ្ជូន

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យ បុរេប្រទាន | ឥណទាន ទូទាត់ ធម្មតា | ឥណទាន០១ ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| | | | សរុបរួម (I+II) | 10,951,400,000 | 10,951,400,000 | 1,859,945,000 | 9,091,455,000 | 464,986,250 | 16.98% |
| | | I | ឥណទានតាមជំពូកមិនគិតបញ្ចូលបេសកកម្មក្នុងប្រទេស | 9,838,400,000 | 9,838,400,000 | 1,042,000,000 | 8,796,400,000 | 260,500,000 | 10.59% |
| 60 | | | ការទិញ | 5,118,400,000 | 5,118,400,000 | 171,000,000 | 4,947,400,000 | 42,750,000 | 3.34% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ | 64,000,000 | 64,000,000 | 29,000,000 | 35,000,000 | 7,250,000 | 45.31% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតអនាម័យ | 4,000,000 | 4,000,000 | 4,000,000 | | 1,000,000 | 100% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទនិងសំណង់ផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 50,000,000 | 50,000,000 | 15,000,000 | 35,000,000 | 3,750,000 | 30.00% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 3,392,000,000 | 3,392,000,000 | 82,000,000 | 3,310,000,000 | 20,500,000 | 2.42% |
| | | 60021 | សម្ភារៈការិយាល័យនិងបោះពុម្ព | 3,380,000,000 | 3,380,000,000 | 70,000,000 | 3,310,000,000 | 17,500,000 | 2.07% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 12,000,000 | 12,000,000 | 12,000,000 | | 3,000,000 | 100% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 1,662,400,000 | 1,662,400,000 | 60,000,000 | 1,602,400,000 | 15,000,000 | 3.61% |
| | | 60051 | សម្ភារៈនិងបរិក្ខាបច្ចេកទេស | 1,544,400,000 | 1,544,400,000 | 36,000,000 | 1,508,400,000 | 9,000,000 | 2.33% |
| | | 60052 | សង្ហារឹម | 100,000,000 | 100,000,000 | 6,000,000 | 94,000,000 | 1,500,000 | 6.00% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 18,000,000 | 18,000,000 | 18,000,000 | | 4,500,000 | 100% |
| 61 | | | សេវាកម្ម | 4,720,000,000 | 4,720,000,000 | 871,000,000 | 3,849,000,000 | 217,750,000 | 18.45% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 6101 | | កិច្ចសន្យានៃការផ្គត់ផ្គង់សេវាជាមួយសហគ្រាស | 5,000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | **6105** | | **ការថែទាំ និង ជួសជុល** | **1,207,000,000** | **1,207,000,000** | **259,000,000** | **948,000,000** | **64,750,000** | **21.46%** |
| | | 61052 | ការថែទាំ និង ជួសជុលអគារផ្សេងៗ និង ប្រាសាទ | 730,000,000 | 730,000,000 | 32,000,000 | 698,000,000 | 8,000,000 | 4.38% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 50,000,000 | 50,000,000 | 50,000,000 | | 12,500,000 | 100% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 300,000,000 | 300,000,000 | 50,000,000 | 250,000,000 | 12,500,000 | 16.67% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និង ឧបករណ៍បច្ចេកទេស | 117,000,000 | 117,000,000 | 117,000,000 | - | 29,250,000 | 100% |
| | | 61058 | ការថែទាំនិងជួសជុលផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | **6110** | | **ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ** | **1,865,000,000** | **1,865,000,000** | **287,000,000** | **1,578,000,000** | **71,750,000** | **15.39%** |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 60,000,000 | 60,000,000 | 18,000,000 | 42,000,000 | 4,500,000 | 30.00% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 80,000,000 | 80,000,000 | 24,000,000 | 56,000,000 | 6,000,000 | 30.00% |
| | | 61103 | ប្រជុំ សិក្ខាសាលានិង សន្និសិទ | 1,600,000,000 | 1,600,000,000 | 120,000,000 | 1,480,000,000 | 30,000,000 | 7.50% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 45,000,000 | 45,000,000 | 45,000,000 | - | 11,250,000 | 100% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ក្នុងនិងក្រៅប្រទេស | 40,000,000 | 40,000,000 | 40,000,000 | - | 10,000,000 | 100% |
| | | 61106 | ចំណាយសម្រាប់តាំងពិព័ណ៌ក្នុងនិងក្រៅប្រទេស | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 20,000,000 | 20,000,000 | 20,000,000 | - | 5,000,000 | 100% |
| | **6111** | | **ចំណាយលើការជាវសាព័ត៌មាននិងឯកសារ** | **5,000,000** | **5,000,000** | **5,000,000** | **-** | **1,250,000** | **100%** |
| | | 61111 | ចំណាយលើការជាវសាព័ត៌មាន | 5,000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | **6113** | | **ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស** | **1,435,000,000** | **1,435,000,000** | **280,000,000** | **1,155,000,000** | **70,000,000** | **19.51%** |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 450,000,000 | 450,000,000 | 120,000,000 | 330,000,000 | 30,000,000 | 26.67% |
| | | 61132 | សោហ៊ុយបេសកកម្ម | 230,000,000 | 230,000,000 | 50,000,000 | 180,000,000 | 12,500,000 | 21.74% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 755.000,000 | 755,000,000 | 110,000,000 | 645,000,000 | 27,500,000 | 14.57% |
| | **6114** | | **សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍** | **203,000,000** | **203,000,000** | **35,000,000** | **168,000,000** | **8,750,000** | **17.24%** |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 5.000,000 | 5,000,000 | 5,000,000 | | 1,250,000 | 100% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 198,000,000 | 198,000,000 | 30,000,000 | 168,000,000 | 7,500,000 | 15.15% |
| | | II | **<u>ឥណទានសំរាប់ចំណាយបេសកកម្មក្នុងប្រទេស</u>** | **1,113,000,000** | **1,113,000,000** | **817,945,000** | **295,055,000** | **204,486,250** | **73.49%** |
| | **6112** | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | **1,113,000,000** | **1,113,000,000** | **817,945,000** | **295,055,000** | **204,486,250** | **73.49%** |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 5,000,000 | 5,000,000 | 5,000,000 | - | 1,250,000 | 100% |
| | | 61122 | សោហ៊ុយបេសកកម្ម | 174,000,000 | 174,000,000 | 130,679,000 | 43,321,000 | 32,669,750 | 75.10% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 934,000,000 | 934,000,000 | 682,266,000 | 251,734,000 | 170,566,500 | 73.05% |

បានឃើញ និង ពិនិត្យត្រឹមត្រូវ

ភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៥

ᨀ. អគ្គនាយក

អគ្គនាយកដ្ឋានរតនាគារជាតិ

អគ្គនាយករង

ម៉ិញ បានសុវណ្ណអាទិច្ចាសីលា

បានឃើញ និង ពិនិត្យត្រឹមត្រូវ

ភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៥

៨. អគ្គនាយក

អគ្គនាយកដ្ឋានថវិកា

លុយ_សុគតិរក្ស

រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៥

បានឃើញ និង ពិនិត្យត្រឹមត្រូវ រដ្ឋលេខាធិការទទួលបន្ទុក

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

អ៊ុក_ច័ន្ទតារា

**បានឃើញ និង ឯកភាព**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អូន ព័ន្ធមុនីរ័ត្ន

**បានឃើញ និង ឯកភាព**

រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

ត្រាំ អ៊ីវតឹក

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ  សាសនា  ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច  និង  ហិរញ្ញវត្ថុ
លេខ..៦៦០.......សហវ.ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងវេជ្ជបណ្ឌិតប្រចាំការ
## របស់ក្រសួងអប់រំ យុវជន និងកីឡា
## នៅនាយកដ្ឋានសុខភាពសិក្សា

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច  និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ  យុវជន  និងកីឡា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤  ខែ កញ្ញា  ឆ្នាំ ២០១៣  ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤  ខែ មករា ឆ្នាំ ១៩៩៦  ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦  ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤  ចុះថ្ងៃទី ៣០  ខែ តុលា  ឆ្នាំ ១៩៩៤  ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី ១៨  ខែ ធ្នូ  ឆ្នាំ ២០១៤  ដែលប្រកាសឱ្យប្រើច្បាប់  ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥
-បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក  ចុះថ្ងៃទី ១៦ ខែ តុលា  ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក  ចុះថ្ងៃទី ០៩ ខែ មិថុនា  ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ  ៨២ អនក្រ.បក    ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥   ស្តីពីបទបញ្ជាទូទៅ    នៃគណនេយ្យសាធារណៈ
-បានឃើញអនុក្រឹត្យលេខ  ៨១ អនក្រ.បក    ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥   ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664    Fax : 855-23-427 798

-បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី ១៥ខែមករាឆ្នាំ១៩៨៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ១៨៥ សហវ.ប្រក ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

-បានឃើញប្រកាសអន្តរក្រសួងលេខ ១៦២ អយក.ប្រក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា

-យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**ប្រការ១:**

ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡាដូចខាងក្រោម:

**១.លោក លី រតនៈ** ឋានៈជាអនុប្រធានការិយាល័យផែនការ ឱ្យទទួលបន្ទុកការងារជា រជ្ជទេយ្យករបុរេប្រទាន

**២.លោកស្រី កាន់ សុធារី** ឋានៈជាមន្ត្រីការិយាល័យរដ្ឋបាល ឱ្យទទួលបន្ទុកការងារជា រជ្ជទេយ្យករបុរេប្រទានរង

**ប្រការ២:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និង ប្រធាននាយកដ្ឋានសុខភាពសិក្សា ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមុខងារសាធារណៈ

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-សាលារាជធានី ខេត្ត

-ដូចប្រការ៣

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៧៩.......ឧស.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ដាលី ហ្គាម៉ិន អ៊ិនធើណេសិនណល (ខេមបូឌា) ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥។

## <u>សម្រេច</u>

**<u>ប្រការ១៖</u>** អនុញ្ញាតឱ្យក្រុមហ៊ុន ដាលី ហ្គាម៉ិន អ៊ិនធើណេសិនណល (ខេមបូឌា) (DALI GARMENT INTERNATIONAL (CAMBODIA) LIMITED.) តំណាងដោយ លោក WU YUNDUI បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិកែវឧត្តម ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកាត់ដេរសម្លៀកបំពាក់ ដាលី ហ្គាម៉ិន អ៊ិនធើណេសិនណល (ខេមបូឌា)"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការ ជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹង វិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាខេត្តកំពង់ស្ពឺ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ..១៧៧០....ឧស.ក.ស្រ.ពគ.០៤

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ជេជាង អ៊ិនដាសស្ទ្រៀល ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ជេជាង អ៊ិនដាសស្ទ្រៀល (JECHIARNG INDUSTRIAL CO., LTD.) តំណាងដោយ លោកស្រី LIN, YI-HSUAN បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ ភូមិត្រពាំងក្រសាំង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ ៖** "រោងចក្រកាត់ដេរសម្លៀកបំពាក់ ជេជាង អ៊ិនដាសស្ទ្រៀល"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឌ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ..១៧៦....ឧស.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ **ផលិតបារី** របស់ក្រុមហ៊ុន ឡូធើស ខេរ៉ឹត ថឹបែកខូ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ឡូធើស ខេរ៉ឹត ថឹបែកខូ (LOTUS CARAT TOBACCO CO., LTD) តំណាងដោយលោក CHEN WEITAO បង្កើតរោងចក្រ ផលិតបារី ដែលមានទីតាំងស្ថិតនៅ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| បារី | ១២០០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**<u>ប្រការ២៖</u>** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រផលិតបារី ឡូជើស ខេរ៉ិត ចឺប៊ែកខូ"

**<u>ប្រការ៣៖</u>** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**<u>ប្រការ៤៖</u>** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**<u>ប្រការ៥៖</u>** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ៦៖</u>** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ៧៖</u>** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ៨៖</u>** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ៩៖</u>** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១០៖</u>** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ...[illegible]...ឧស.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០១៥

## ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតស្បែកជើង របស់ក្រុមហ៊ុន ជេ.អិន.ធី ស៊ូ ហ្វេកធើរី (ខេមបូឌា) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១ៈ** អនុញ្ញាតឱ្យក្រុមហ៊ុន ជេ.អិន.ធី ស៊ូ ហ្វេកធើរី (ខេមបូឌា) (J.N.T SHOES FACTORY (CAMBODIA) Co., Ltd.) តំណាងដោយ លោក TSENG, TE-HENG បង្កើតរោងចក្រ ផលិតស្បែកជើង ដែលមានទីតាំងស្ថិតនៅ ភូមិអង្គសុគន្ធា ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| ស្បែកជើង | ១៥២០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រផលិតស្បែកជើង ជេ.អិន.ធី ស៊ូ ហ្វេកធើរី (ខេមបូឌា)"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្ដិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្ដល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្ដន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ